# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ដ្រ

ឆ្នាំទី ២៥ ខែមិថុនា លេខ ៦

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

### ផ្នែកសាសនា


| | | |
|---|---|---|
| — មិត្តកថា .................... | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ៤០៣ |
| — កឋិនកថា (តមក) .............. | ព្រះមហាឧត្តមវិជ្ជា កែ - អៀន .. | ៤១៨ |


### ផ្នែកអក្សរសាស្ត្រ


| | | |
|---|---|---|
| — ការបណ្ដុះនិស្ស័យ (តមក) ....... | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ៤២៣ |
| — រឿងសាមកុក (តមក) .......... | ឧកញ៉ា ទូ - កន ......... | ៤២៨ |
| — រឿងអាវ័ក្សថ្លែងរឿងម្ដេច្រាំ (តមក) ... | លោក រ៉ាយ - ប៊ុក ......... | ៤៣៣ |
| — រឿងស្លាប់ព្រោះជាតិ (តចប់) ....... | លោក គង់ — លឹម ........ | ៤៤៣ |
| — រឿងចិញ្ចៀនទិព្វ .............. | អ្នកស្រីសារីយ៉ាន់ ......... | ៤៥៣ |
| — រឿងប៉ូលនឹងវីរ័ស៊ីនី (តមក) ....... | លោក ផេង - ជ្រឹវ ........ | ៤៥៨ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ .. | ពុទ្ធសាសនបណ្ឌិត្យ ....... | ៤៦៣ |


### កំណត់ទីនប្រវត្តិការណ៍


| | | |
|---|---|---|
| — សុន្ទរកថាបណ្ឌិតម៉ាឡាឡ៉ះសេកេរះថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ... | ៤៧០ |
| — ពិធីបុណ្យឆ្លងព្រះវិហារ វត្តពោធិវាល ខេត្តបាត់ដំបង ............. | ព្រះមហាឧត្តមវិជ្ជា កែ - អៀន ... | ៤៧៥ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE

Pages

— Mittakatha.................. *Brah Maha Peung-PAM.......* 403
— Kathinakatha (suite)........ *Brah Maha Ker-œun . . . . .* 418

### PARTIE LITTERAIRE

— Education morale (suite).... *Brah maha Peung-Pam. . . . .* 423
— Histoire de SAMKOK (suite).. *Oknha Nou-Kan . . . . . . .* 428
— Les vingt cinq récits du Mauvais Génie (suite) ........... *M. Ray-Buc . . . . . . . . .* 433
— Mort pour la patrie (fin) .... *M. Kong-Lim . . . . . . . . .* 443
— La bague magique.......... *Mme SARIS-YANN...........* 453
— Paul et Virginie (suite) ...... *M. Phéng-Chrieu . . . . . . .* 458
— L'activité de la Commission des Mœurs et Coutumes ........ *Institut Bouddhique . . . . . .* 463

### NOTES ET CHRONIQUES

— Discours du Dr. MALALASEKERA au 2e Congrés Mondial Bouddhique (suite)......... *Institut Bouddhique . . . . .* 470
— Gérémonie d'inauguration du temple de Vat Poveal........ *Prah Maha Ker-Œurn........* 475

Prix d'abonnement annuel comprenant 12 numéros : 192$00

# មិត្តកថា

## ព្រះមហាឧត្តមវិជ្ជា [illegible]លញាណោ ប៊ុង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ*

ទេសនាជាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើតខែផល្គុន ឆ្នាំជូតសំរិទ្ធិស័ក

ព.ស. ២៤៩១ (១៣-៣-៤៩)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមត្ថុ រតនត្តយស្ស

សូមនមស្ការ បំពោះប្រជុំ ៣ នៃព្រះរតនៈដោយគោរព ។

*ពេលនេះ អាត្មាភាពនឹងសំដែងព្រះធម្មទេសនា ពណ៌នាអំពី “មិត្តកថា” ផ្សាយតាមវិទ្យុកម្ពុជា ថ្វាយបំពោះទ្រង់ នឹងចែកជូនដល់អស់លោក-អ្នកទាំងឡាយ តាមន័យពុទ្ធភាសិតថា:*

អត្ថម្ហិ ជាតម្ហិ សុខា សហាយា

*“សំឡាញ់ទាំងឡាយ អាចនាំសេចក្ដីសុខមកឲ្យ*

*ក្នុងពេលដែលសេចក្ដីត្រូវការកើតឡើង” ។*

### មុនដំបូងសូមពណ៌នាអំពី

### ហេតុដែលនាំឲ្យស្វែងរកមិត្តសំឡាញ់

*នរជនដែលកើតឡើងក្នុងលោកសន្និវាស មិនចំពោះជាតិណា សាសន៍ណា សុទ្ធតែត្រូវមានមិត្តសំឡាញ់គ្រប់ៗគ្នាទាំងអស់, នឹងនៅធំតែ*

ម្នាក់ឯងពុំបាន, ព្រោះដំបូងយើងត្រូវអាស្រ័យអាហារជាគ្រឿងឧបត្ថម្ភជីវិត, ក្រៅពីនេះ ត្រូវអាស្រ័យគ្រឿងស្លៀកដណ្ដប់ ទីនៅអាស្រ័យនឹងថ្នាំកែរោគ ដែលហៅថាបច្ច័យ ៤ គឺគ្រឿងអាស្រ័យដើម្បីធ្វើជីវិតឲ្យបានទទួលសេចក្ដីសុខដ៏ពេញលេញ តាមសមគួរដល់អត្តភាព ។ បើពោលយ៉ាងខ្លីទៅ គឺយើងត្រូវអាស្រ័យវត្ថុអម្បាលនេះជានិច្ចខានពុំបាន ។ កាលបើដូច្នេះ យើងនឹងនៅតែម្នាក់ឯងដូចម្ដេចកើត, ព្រោះថាកាលបើយើងមិនពឹងអ្នកដទៃហើយ យើងនឹងធ្វើជីវិតរបស់យើង ឲ្យប្រព្រឹត្តទៅដោយសួស្ដីពុំបានឡើយ មុខជាស្លាប់មិនខាន ។ ថ្បិតជីវិតក្នុងវ័យក្មេងនៅមិនទាន់មានសេចក្ដីដឹង សេចក្ដីអង់អាចដែលនឹងចិញ្ចឹមជីវិតដោយខ្លួនឯងទេ ។ យើងត្រូវអាស្រ័យអ្នកដទៃ គឺមាតាបិតា, បើយើងមិនអាស្រ័យគេទេ តើនឹងបានអាហារពីណាបរិភោគ, បានសំពត់ពីណាស្លៀកដណ្ដប់, បានថ្នាំពីណាកែរោគ, បានទីណាអាស្រ័យនៅ, បាននរណាថែរក្សា ។ សូម្បីយើងបានរស់រួចជីវិត មានវ័យធំធាត់ឡើងដោយអាស្រ័យអតិបិយមិត្តខាងដើមគឺមាតាបិតា ចិញ្ចឹមថែរក្សាមកហើយក៏ដោយ, យើងក៏ត្រូវតែរកសេពគប់មិត្តសំឡាញ់ដំពូកដទៃតទៅទៀត ។ ព្រោះកិច្ចការគ្រប់យ៉ាង មិនមែនសុទ្ធតែធ្វើម្នាក់ឯងកើតទេ មានការងារខ្លះហួសវិស័យនឹងសមត្ថភាពដែលបុគ្គលម្នាក់ៗ ធ្វើឲ្យសម្រេចទាន់កាលបាន, បើយើងមិនមានមិត្តសំឡាញ់ជួយធ្វើទេ តើយើងនឹងធ្វើកិច្ចការទាំងនោះ

ឲ្យសម្រេចដូចម្តេច, ដូច្នេះ ទើបយើងត្រូវមានសំឡាញ់ជាកល្យាណមិត្តសម្រាប់ជួយធ្វើ ៗ សូម្បីបុរាណាចារ្យ ក៏លោកបានពោលទុកមកថា "បើហួសកម្លាំងនឹងលី ត្រូវហាមាត់ស្តីភៀវឲ្យជួយរែកជួយសែង" ដូច្នេះ ៗ ហេតុនេះមនុស្សជាតិដែលកើតឡើងក្នុងលោកសន្និវាសនេះ ទីងចិញ្ចឹមជីវិតរបស់ខ្លួន ឲ្យបានទទួលសេចក្តីសុខ សេចក្តីចំរើនព្រមទាំងសេចក្តីលូតលាស់ ត្រូវតែអាស្រ័យអ្នកដទៃជាកម្លាំងជាពប ៗ ដំបូងត្រូវអាស្រ័យមាតាបិតាជាអ្នកឲ្យកំណើត តទៅត្រូវអាស្រ័យគ្រូអាចារ្យជាអ្នកឲ្យដម្បូន្មានប្រៀនប្រដៅ ដើម្បីឲ្យមានចំណេះវិជ្ជា សេចក្តីចេះដឹង សេចក្តីអង់អាច រហូតដល់ដឹងបាបបុណ្យគុណទោសដែលជាផ្លូវល្អឬផ្លូវអាក្រក់ចំពោះខ្លួន; ហេតុទាំងអម្បាលនេះឯង "ជាហេតុដែលនាំឲ្យស្វែងរកមិត្តសំឡាញ់" ។

## ពិធីសង្កេតមិត្ត

អ្នកដែលស្វែងរកសំឡាញ់បានហើយ ត្រូវពិនិត្យរកសំឡាញ់ដែលមានថ្នាក់ជាមិត្តថែមទៀត ៗ ការសង្កេតរកមនុស្សដែលគួរហៅថាជាមិត្ត ត្រូវសង្កេតដូច្នេះ គឺជនណាដែលជាកៀនរួមការងារជាមួយគ្នា ជននោះលោកឲ្យឈ្មោះត្រឹមតែសំឡាញ់ប៉ុណ្ណោះ, មិនឲ្យឈ្មោះជាមិត្តឡើយ; លុះតែអ្នកណាដែលជាអ្នកស្និទ្ធស្នាលទុកចិត្តគ្នា គឺមានសាមគ្គីចិត្ត

មិត្តធម៌ដល់គ្នានឹងគ្នា អ្នកនោះទើបគួរហៅថាមិត្តបាន ។ ខសំខាន់ដែលត្រូវដឹងគឺសម័យដែលខ្លួនមានធុរៈកើតឡើង បើនរណាមានទឹកចិត្តអើពើជួយធ្វើកិច្ចការទាំងនោះឲ្យសម្រេចបាន ដោយសំដែងទឹកចិត្តដ៏បរិសុទ្ធអាណិតអាសូរមិនបាច់ពឹង អ្នកនោះទើបហៅថាមិត្ត; អ្នកដែលជួយអំពីនេះមិនគួរហៅថាមិត្តទេ ។

ដើម្បីនឹងពិនិត្យឲ្យដឹងថា នរណាជាមិត្ត នរណាមិនមែននោះ សូមនាំយកភាសិតអំពីនីតិរបស់ចាណក្យព្រាហ្មណ៍ មកដាក់ក្នុងទីនេះជាគ្រឿងសង្កេត :

១.— នៅស្ងៀមៗ នរណាមិនជាមិត្តរបស់នរណា ហើយនរណាក៏មិនជាសត្រូវរបស់នរណា; លុះតែមានហេតុកើតឡើងទើបដឹងបានថា នរណាជាមិត្ត នរណាជាសត្រូវ ។

២.— បង់ដឹងខ្ញុំកំដរឲ្យមើលក្នុងពេលធ្វើការងារ, បង់ដឹងវង្សត្រកូលឲ្យមើលក្នុងពេលដែលខ្លួនបានទុក្ខ, បង់ដឹងមិត្តសំឡាញ់ឲ្យមើលក្នុងពេលមានធុរៈ ឬអន្តរាយ, បង់ដឹងភរិយាឲ្យមើលក្នុងពេលខ្សត់ទ្រព្យសម្បត្តិ ។

គោលសំខាន់ពីរខនេះ ជាគ្រឿងប្រដាប់សម្រាប់សង្កេតរកឋានៈរបស់មនុស្សដែលត្រូវជាមិត្ត; ដើម្បីនឹងសង្កេតមិត្តឲ្យបានច្បាស់លាស់

តទៅទៀតត្រូវពិនិត្យគេលក្ខណៈរបស់មិត្ត; ព្រោះការសេពគប់មិត្តមិនមែនសុទ្ធតែបានផលប្រយោជន៍ខាងល្អមួយចំណែកទេ មានជួនកាលត្រឡប់ជាឲ្យបាននូវសេចក្ដីវិនាសទៅវិញ ស្រេចហើយតែអ្នកសេពគប់ ប៉ះទៅលើមិត្តល្អ ឬ មិត្តអាក្រក់ ។

មិត្តណាដែលធ្វើសេចក្ដីវិនាស ឲ្យកើតឡើងដល់ខ្លួនទីងអ្នកដទៃទាំងក្នុងលោកនេះនិងលោកខាងមុខ មិត្តនោះបាត់ជាមិត្តអាក្រក់ មិនគួរសេពគប់ ។ មិត្តណាធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួននិងអ្នកដទៃទាំងក្នុងឥធលោកនិងបរលោក មិត្តនោះបាត់ថាជាមិត្តល្អគួរសេពគប់ ។

អស់លោកទាំងឡាយ កាលបានជ្រាបដូច្នេះហើយ បើប្រាថ្នាប្រយោជន៍ ដ៏ធំទូលាយដល់ខ្លួនទីងប្រទេសជាតិ សូមកុំសេពគប់នឹងមិត្តអាក្រក់ឡើយ សូមសេពគប់តែនឹងមិត្តល្អ ១ ចំណែក ឲ្យសមគ្នានឹងគោលធម៌ក្នុងធម្មបទថា:

"មិនត្រូវសេពគប់បាបមិត្ត
មិនត្រូវធ្វើស្និទ្ធនឹងមិត្តអធម:
ត្រូវគប់តែមិត្ត កល្យាណ:
ហើយនឹងភឿនភក្តិថ្នាក់ឧត្តម" ។

គោលសំខាន់ ១ នេះ ជាគ្រឿងរំឭកមនុស្សកុំឲ្យសេពគប់នឹងបាបមិត្តឲ្យសេពគប់តែមិត្តល្អម្យ៉ាង, ព្រោះមិត្តដែលលោកបាត់ថាជា កល្យាណ-

មិត្តនោះ តែងជួយដឹកនាំគៀនក្នុងផ្លូវដែលល្អ ទំនងជួយការពារមិនឲ្យសេចក្តីអន្តរាយកើតឡើង តាមលក្ខណៈដែលលោកចែកទុកដូចេះថា:

អហិតា ត្បេតិ មេធគ្គូ
ហិតេ ចាតុប្បវតិនមិ
វ្យសនេ នាបរិត្យាត-
ស្ត្រៈបធំ មិត្រលក្សណាមិ

"លក្ខណៈរបស់មិត្តល្អមាន ៣ យ៉ាង គឺ: ១- ហាមឃាត់មិត្ត មិនឲ្យធ្វើអំពើឥតប្រយោជន៍ ២- ណែនាំមិត្តឲ្យធ្វើតែអំពើមានប្រយោជន៍ ៣- ពេលមានហេតុកើតឡើង មិនលះបង់គ្នា" ។

លក្ខណៈរបស់មិត្តល្អ ៤ យ៉ាងដោយឡែកទៀត គឺ:

១ ការពារគៀន ដែលភ្លេចស្មារតី

២- ការពារទ្រព្យសម្បត្តិ ដែលគៀនធ្វេសប្រហែស

៣- កាលមានភ័យ អាចជាទីពឹងពំនាក់បាន

៤- កាលមានធុរៈកើតឡើង បានមកជួយដោយមិនបាច់ពឹង ។

មិត្តសំឡាញ់ដែលមានលក្ខណៈដូចេះ បណ្ឌិតគួរសេពគប់ដើម្បីបានជាកំឡាំងជួយគ្នាទៅវិញទៅមក ក្នុងសម័យដែលមានទុក្ខធុរៈ ។

# ការសេពគប់មិត្ត

ដោយគុណានុភាពនៃមិត្តដូច្នេះ បានជាមនុស្សជាតិត្រូវតែរកសេពគប់មិត្ត ៗ ក៏ការដែលសេពគប់មិត្តនេះ គឺការធ្វើសេចក្ដីស្និទ្ធស្នាលឲ្យកើតឡើងដល់គ្នានឹងគ្នា រហូតដល់ទុកចិត្តគ្នា ដោយប្រាថ្នាល្អទៅវិញទៅមក ៗ ការគប់មិត្តមិនចំពោះបុគ្គល ១ រូបៗ ឡើយ, ដោយហោចទៅ សូម្បីមិត្តសំឡាញ់ដែលកើតជាមួយគ្នា ឬ ដែលកើតខាងក្រោយក៏ត្រូវអាស្រ័យគ្នាដែរ មិនរើសថាជាតិ, សាសនា, ភាសាជាមួយគ្នា ឬ ផ្សេងជាតិ ផ្សេងសាសនា, ផ្សេងភាសា, ផ្សេងស្រុក, ផ្សេងនគរឡើយ ឲ្យតែសម្ពន្ធភាពល្អមផ្សាយទៅបាន ទីបំផុតគឺទូទៅទាំងសកលលោក; ការអាស្រ័យនូវគ្នានឹងគ្នា នឹងប្រព្រឹត្តទៅបែបណាក៏ដោយ ក៏ហៅថាសម្ពន្ធភាពដែរ; សម្ពន្ធភាពនេះជាគ្រឿងបង្គាប់មនុស្សទាំងឡាយ មិនឲ្យនៅតាមទំនើងចិត្ត, ដំពូកខ្លះក៏ជាកិច្ចឬនាទីធម្មតា ដែលមនុស្សត្រូវធ្វើតាមឋានានុរូបដែលជាប់ទាក់ទងគ្នាយ៉ាងណាមួយ, ដំពូកខ្លះក៏ជាកិច្ចឬនាទីយ៉ាងធំបំផុត ដែលនរជនត្រូវធ្វើខានពុំបាន, ដូច្នេះ ឃើញថា "មនុស្សជាតិក្នុងលោកនេះនឹងនៅតែម្នាក់ឯងពុំបានទេ" សូម្បីមានពុទ្ធដីកាដែលយើងធ្លាប់ដឹងស្ទើរតែគ្រប់គ្នាមកហើយថា "អត្តា ហិ អត្តនោ នាថោ ខ្លួនឯងជាទីពឹងរបស់ខ្លួន, កោ ហិ នាថោ បរោ សិយា អ្នកដទៃណាមួយនឹងជាទីពឹងរបស់ខ្លួនបាន" ដូច្នេះគឺ សេចក្ដីនៃភាសិតពីរខនេះ ក៏មានន័យដោយ

ខ្សែក គឺជាបុព្វហេតុ សម្រាប់ទូន្មានមនុស្សឲ្យបង្ហាត់ខ្លួនឲ្យបានល្អម្ទន ហើយ សមតឹងអ្នកដទៃជាខាងក្រោយ, ព្រោះកាលបើយើង គ្មានគុណសេចក្ដីល្អកងខ្លួនទេ តើនរណាមួយនឹងជាទីពឹងរបស់យើងបាន ។

ដើម្បីនឹងយកប្រយោជន៍ ដ៏ពេញលេញអំពីសម្ពន្ធភាពដែលកើតឡើងដល់មនុស្សយើង, "មិត្តភាព" ដែលជាគុណធម៌ ១ សម្រាប់បណ្ដុះបញ្ញា, បណ្ដុះសេចក្ដីជឿនឹងសេចក្ដីជ្រះថ្លា ទើបត្រូវមានគុណធម៌គឺសាមគ្គីចិត្ត, មេត្តាចិត្ត, ករុណាចិត្តនឹងមិត្តធម៌ ចំពោះភ្ញៀនមិត្តភក្ដិទាំងឡាយចូលមកឧបត្ថម្ភថែមទៀត ។

## គុណធម៌សម្រាប់ផ្សារមិត្តភាពឲ្យជាប់គ្នា

សាធុជនទាំងឡាយ សូមជ្រាបថា "សម្ពន្ធភាព" តែងប្រព្រឹត្តទៅដោយឋាន: ២ យ៉ាង គឺ ដោយធម្មតា ១ ដោយការបង្កើតថ្មី ១ ។

ព្រះរាជានឹងប្រជារាស្ត្រ, មាតាបិតានឹងបុត្រធីតា, ស្វាមីនឹងភរិយាព្រមទាំងញាតិសន្តានជាមិត្តនឹងគ្នា ឬ នាយចៅហ្វាយនឹងបាវព្រាវ, គ្រូអាចារ្យនឹងសិស្សានុសិស្ស ក៏ជាមិត្តនឹងគ្នាដែរ; មិត្តចំពូកនេះ ចាត់ថាជា "មិត្តដោយធម្មតា" ។

ការចងមិត្តនឹងអ្នកដទៃ មិនចំពោះមនុស្សម្នាក់ៗ ឬជាតិជាមួយគ្នាដរាបដល់ប្រទេស ចងស្ពានមេត្រីនឹងប្រទេសឯទៀត; មិត្តបែបនេះចាត់ថាជា "មិត្តដែលត្រូវបង្កើតថ្មី" ។

ការសេពគប់មិត្តទាំង ២ បំពូកនេះ ក៏ដើម្បីនឹងជួយក្រោគ្នាទៅវិញទៅមក ឲ្យបានសេចក្តីចម្រើនលូតលាស់ទាន់សម័យ; តែថា សូម្បីមិត្តដែលធម្មតាតែងមកហើយក៏ដោយ ក៏នៅតែមានកាលខ្លះបែកបាក់គ្នាទៅវិញ, ដូចជាធ្លាប់ប្រាប់មកហើយថា ព្រះពជានឹងបណ្តាកស្ត្រីកើតស្អប់គ្នាក៏មាន, មាតាបិតានឹងបុត្រធីតាកាត់កាល់គ្នាចោលក៏មាន, ភរិយានឹងស្វាមីលះលែងគ្នារហូតដល់ប្រកួតប្រកាន់គ្នាក៏មាន ។ ញាតិសន្តានបងប្អូនក្លាយជាសត្រូវបំផ្លាញគ្នាទៅវិញទៅមកក៏មាន, មិត្តសំឡាញ់អ្នករួមកិច្ចការជាមួយដោយឋានៈជាអ្នកបង្គាប់បញ្ជានឹងអ្នកតូច ដែលនៅក្រោមបង្គាប់បញ្ជាបែកសាមគ្គី មិនមានសេចក្តីស្រឡាញ់មូលមិត្តនូវគ្នានឹងគ្នាក៏មាន; ករណីអម្បាលនេះ សឲ្យឃើញថា: សូម្បីតែឋានៈ ដែលធម្មតាតែងមកស្រាប់នោះ គង់មិនអាចនឹងអំណោយនូវសេចក្តីសុខសេចក្តីចំរើនដល់គ្នានឹងគ្នាជានិច្ចទេ ។ ដើម្បីនឹងធ្វើមិត្តដោយធម្មតានឹងមិត្តដែលត្រូវបង្កើតថ្មី ឲ្យជាប់គ្នាឋិតថេរទៅបាន, ត្រូវអាស្រ័យទឹកបន្សាបបានដល់សាមគ្គីចិត្តមិត្តធម៌ គឺចិត្តដែលស្រុសស្រួល មានសេចក្តីស្រឡាញ់អាណិតអាសូរប្រាថ្នាល្អដល់គ្នានឹងគ្នា ជាគុណធម៌ចូលមកផ្សារមួយជាន់ទៀត ទើបសម្ពន្ធភាពដែលមានហើយនោះ នឹងចូលគ្នាយ៉ាងជិតស្និទ្ធល្មមនឹងទទួលសន្តិសុខជានិច្ចទៅ ។

ទឹកបន្សាបគឺគុណធម៌ទាំងនោះ ត្រូវប្រើដូច្នេះ គឺមិនចំពោះតែអ្នកដែលមានឋានៈខាងអាជីពស្មើគ្នា ឬតូចធំជាងគ្នាឡើយ គួរតែធ្វើសាមគ្គី

បិត្តមិត្តធម៌ ឲ្យប្រព្រឹត្តទៅរវាងគ្នានឹងគ្នា តាមឋានានុរូបកុំខាន បើមានជាអ្នកតូច មិត្តដែលជាអ្នកធំ គួរតាំងនៅក្នុងមេត្តាករុណា, ព្រោះជាធម៌មានគុណានុភាព សមគួរដល់លក្ខណៈរបស់អ្នកធំ ៗ ឯមិត្តដែលជាអ្នកតូចវិញក៏គួរតាំងចិត្ត ទទួលស្តាប់បង្គាប់ដោយយកចិត្តទុកដាក់ តាមឋានៈរបស់ខ្លួនដែរ ៗ ចំណែកមិត្ត ដែលតាំងនៅក្នុងឋានៈស្មើគ្នា ត្រូវយកគំនិតទុកដាក់ជួយថែរក្សា, ជួយការពារ, ជួយដាស់តឿនគឿនមិត្តភក្តិរបស់ខ្លួនដែលភ្លេចស្មារតី, ជួយរំលឹក, ជួយណែនាំ, ជួយរក្សាដំណែងនាទីការងារទ្រព្យសម្បត្តិឲ្យគ្នានឹងគ្នា; កាលមានធុរៈ ឬ ភយន្តរាយកើតឡើង អាចជាទីពឹងបាន, មិនលះបង់គ្នាក្នុងគ្រាមានវិបត្តិ, ព្រមទាំងរាប់អានរហូតដល់វង្សត្រកូលរបស់មិត្ត ៗ

ជនអ្នកសេពគប់មិត្ត កាលប្រព្រឹត្តតាមធម៌នេះហើយ, រមែងធ្វើសម្ពន្ធភាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅ ដោយសួស្តីជានិរន្តរ៍បាន ៗ ដូច្នេះឃើញថា: សាមគ្គីចិត្តមិត្តធម៌នេះ មានគុណានុភាពយ៉ាងសំខាន់ មិនត្រឹមតែធ្វើមនុស្សដែលជាផៅពង្សជាមួយគ្នា ឲ្យជាមិត្តនឹងគ្នាប៉ុណ្ណោះទេ ថែមទាំងផ្សារមនុស្សដទៃនឹងមនុស្សដទៃ ឲ្យជាមិត្តនឹងគ្នាបានទៀតផង ៗ

## ប្រយោជន៍នៃការសេពគប់មិត្ត

មិត្តជាគ្រឿងកក់ក្តៅចិត្តយ៉ាងធំបំផុត មិនចំពោះតែមនុស្សទេ សូម្បីយានពាហនៈនិងវត្ថុដែលយើងមានស្រាប់ ឬ គុណធម៌ គឺ បុណ្យ

កុសល គឺជាមិត្តរបស់យើងដែរ ព្រោះមានឥទ្ធានុភាព និងសមត្ថភាព អាចធ្វើឲ្យចិត្តកក់ក្ដៅបាន, សមដូចជាពុទ្ធភាសិតខ្លះ ក្នុងធម្មបទថា:

"ពួករទេះជាមិត្ត របស់មនុស្សអ្នកដើរផ្លូវ;
បុណ្យកុសលទាំងឡាយ ដែលធ្វើទុកដោយខ្លួនឯង
ជាមិត្តជិតតាមខ្លួនទៅក្នុងកពខាងមុខ" ។

គុណានុភាពនៃការសេពគប់មិត្តសំឡាញ់ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ នៅមានទៅទៀតច្រើនជាអនេក តែក្នុងទីនេះ សូមពណ៌នាដោយសង្ខេប ។

មនុស្សយើងដែលអាស្រ័យនៅក្នុងសកលលោក ចាប់តាំងពីផ្ទះមួយខ្នងឡើងទៅរហូតដល់ភូមិ, ឃុំ, ស្រុក... និងប្រទេសជាតិ ដទៃពីគ្នា ក៏ត្រូវតែអាស្រ័យគ្នាជួយគ្នា ក្នុងកិច្ចការផ្សេងៗ ច្រើនខ្លះតិចខ្លះ តាមសមត្ថភាពរបស់ខ្លួន, ដូចអស់លោកជ្រាបស្រាប់ហើយ បច្ចុប្បន្នសម័យនេះគ្រប់តែប្រទេស មិនកំណត់ថាជិតឬឆ្ងាយ គេកំពុងតែត្រូវការណាស់ខាងការផ្សាយមិត្តភាពរកគ្នានិងគ្នា ដើម្បីទទួលយកដោយពេញចិត្ត នូវវិទ្យាសាស្ត្រ សេចក្ដីចេះដឹងនិងការស៊ីវិល្ស ដែលជាមូលហេតុនៃសេចក្ដីសុខ សេចក្ដីចំរើន មកដាក់ក្នុងប្រទេសរបស់ខ្លួន តាមនិស្ស័យនៃម្ចាស់ប្រទេស ឥតប្រទេសណាមួយនៅធំតែឯងទេ, ព្រោះមិត្តភាពនេះ ជាកម្លាំងខាងក្រៅមួយយ៉ាងធំបណ្ដាច់ដែលនឹងធ្វើអ្នកសមាគមឲ្យ

ផលទៅសេចក្តីចំរើន ឬ សេចក្តីវិនាស ។ សូម្បីព្រះសម្មាសម្ពុទ្ធក៏ទ្រង់ត្រាស់ហើយថា “ម្នាលភិក្ខុទាំងឡាយ ! កាលធ្វើបច្ច័យខាងក្រៅឲ្យជាហេតុហើយ តថាគតមិនឃើញហេតុដទៃ សូម្បីណាមួយដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសយ៉ាងធំឲ្យដូចជាការមានមិត្តអាក្រក់នេះឡើយ, ការមានមិត្តអាក្រក់ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសយ៉ាងសម្បើម” នឹងទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ! តថាគតមិនដែលឃើញហេតុដទៃ សូម្បីណាមួយដែលនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ ឲ្យដូចជាការមានមិត្តល្អនេះ; ការមានមិត្តល្អ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ឱឡារិក” ។ ដោយអាស្រ័យពុទ្ធភាសិតប៉ុណ្ណេះជាគ្រឿងអាង ក៏ល្មមសឲ្យឃើញថា: ការសេពគប់មិត្ត ជាកម្លាំងមួយយ៉ាងធំបំផុត, មិនចំពោះតែបុគ្គលមួយរូបៗ ឡើយ; ការសេពគប់លើមិត្តអាក្រក់ ផ្សាយទៅដល់សង្គមណា រដ្ឋណា, សេចក្តីវិនាស, សេចក្តីសាបសូន្យ, ការក្តៅក្រហាយចិត្ត រមែងមានក្នុងសង្គមនោះរដ្ឋនោះ; ការសមាគមដោយមិត្តល្អប្រព្រឹត្តទៅដល់ក្រុមណា ដែនណា ប្រទេសណា, សេចក្តីសុខ, សេចក្តីចំរើន, ការកក់ក្តៅចិត្ត តែងមានដល់ក្រុមនោះ ដែននោះ ប្រទេសនោះ ។ ដោយគុណានុភាពនៃការមានមិត្តសំឡាញ់ដូច្នេះ បានជានរជនត្រូវបណ្តុះសាមគ្គីធម៌ គឺ សេចក្តីព្រមព្រៀងគ្នាស្រុះស្រួលគ្នា ដែលជាគ្រឿងបណ្តុះមិត្តភាពនោះឲ្យមានពេញពោរឡើង

ចំពោះពួកគៀនមិត្តភក្តិ ផ្ទះ, ភូមិ, ឃុំ, ស្រុកទីងប្រទេសជាតិជិតខាង ទើបទឹងនាំយកនូវសេចក្តីសុខសម្រាន្ត មកកាន់ពួកគណៈរបស់ខ្លួនដោយបរិបូរណ៍, សូម្បីព្រះសម្មាសម្ពុទ្ធដែលជាធម្មស្សាមី ក៏ទ្រង់សំដែងអំពីអានិសង្ស នៃសាមគ្គីនោះដែរថា: សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងនៃពួកគណៈ រមែងឲ្យកើតសុខ, សមគ្គានំ សង្ឃានំ តបោ សុខោ ... សាមគ្គី វុឌ្ឍិសាធិកា ការស្រុះស្រួលមូលមិត្តនៃជនទាំងពួងដែលជាពួកគណៈអាចញុំាងសេចក្តីចំរើនឲ្យកើតបាន ។

ប្រទេស ជាតិ សាសនា មហាក្សត្រទឹងរដ្ឋធម្មនុញ្ញ អាចទឹងតាំងនៅយឺនយូរបាន កំព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌របស់ប្រជាជាតិទាំងមូលដែលបានស្រុះស្រួលពួតដៃគ្នា ជួយថែរក្សាដោយភាពជាកល្យាណមិត្តបែបណាមួយ ។

សាធុជនទាំងឡាយ ដូចបានជោបស្រាប់ហើយ សេចក្តីថ្កុំថ្កើងរុងរឿង, ការល្បីខ្ទរខ្ទាយយ៉ាងឲ្យារិក ដោយកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតនៃកម្ពុជរដ្ឋ ដកបដល់ប្រទេសជិតខាងទទួលដឹងពត្តតាមប្រវត្តិសាស្ត្រ, សាវតារសាស្ត្រកង់សម័យកន្លងទៅហើយ ដែលមានប្រាសាទបុរាណខ្វះជាតួយ៉ាងស្រាប់កើតឡើងបាន កំព្រោះអាស្រ័យសាមគ្គីចិត្តរបស់កម្ពោជិកជនទាំងមូល ដែលបានព្រមព្រៀងពួតដៃគ្នាដោយការបង្គាជាមិត្តកង់សម័យនោះ ។

ការសាបរលាប, ការអាប់ឱនរស្មីនៃប្រទេសកម្ពុជា ក្នុងសម័យមុននេះបន្តិចនោះកើតមានឡើង ក៏ព្រោះការបែកសាមគ្គីនៃកម្ពោជិកជនដែលមិនបានស្រុះស្រួលចងបាច់គ្នាដោយមិត្តភាព ។

ការបានរើបៗ ឡើង, ការមានពន្លឺស្វាងរុងរឿងបន្តិចឡើងវិញក្នុងសម័យឥឡូវនេះ កើតឡើងបានក៏ព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌របស់អ្នកកម្ពុជាភាគច្រើន ។ បើគ្រាន់តែជនភាគច្រើន មានសាមគ្គីចិត្តមិត្តធម៌ចំពោះគ្នានឹងគ្នាប៉ុណ្ណោះប្រភានៃប្រទេសកម្ពុជាបានរើបៗ ឡើងយ៉ាងនេះទៅហើយ ចំណង់បើកម្ពោជិកជនទាំងមូលបានស្រុះស្រួលព្រមព្រៀងគ្នាទៀត តើពន្លឺនៃប្រទេសកម្ពុជានឹងមានយ៉ាងណាទៅ ។

មិនត្រឹមតែសម័យបច្ចុប្បន្នទេ សូម្បីក្នុងសម័យព្រេងនាយក៏សាមគ្គីចិត្តមិត្តធម៌ អាចហុចឲ្យដោយមិនបាច់សូម នូវជ័យជំនះនឹងសេចក្តីរុងរឿងយ៉ាងខ្ពង់ខ្ពស់ដល់ប្រទេសជាច្រើន ដែលបានចងបាច់គ្នាដោយមិត្តភាពដែរ តែថាដោយប្រទេសទាំងនោះ មានជនជាតិបែកសាមគ្គីគ្នាក្នុងខាងក្រោយ, ក៏ត្រូវទទួលបរាជ័យវិញ; គួរយ៉ាងដូចស្តេចលិច្ឆវី ដែលបានទទួលដោយមិនបាច់ខំប្រឹងប៉ុន្មាន នូវជ័យជំនះអំពីព្រះបាទអជាតសត្រូវជក៏ព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌នៃប្រជាក្រស្តរបស់ព្រះអង្គ; តែពេលក្រោយត្រឡប់ជាបរាជ័យចាញ់ព្រះបាទអជាតសត្រូវជវិញ ក៏ព្រោះបណ្តាក្រស្តរបស់ព្រះអង្គបែកសាមគ្គីគ្នា ។

អធិប្បាយមកប៉ុណ្ណេះ ក៏ល្មមឃើញបាន ថាការសេពគប់មិត្តល្អ មានផលប្រយោជន៍ជាអនេក ព្រោះអាចនឹងជួយធុរៈគ្នាទៅវិញទៅមកក្នុងការដែលធ្វើរបស់ហួសវិស័យមនុស្សម្នាក់ៗ ឲ្យសម្រេចទាន់សម័យបាន; ជួយការពារគ្នាក្នុងពេលដែលមានភយន្តរាយកើតឡើង នឹងជួយការពារនូវកិត្តិយសនៃគ្នានឹងគ្នា ព្រមទាំងប្រទេសជាតិឲ្យគង់វង្សបានដង់, បានជាព្រះភគវន្តមុនីទ្រង់ទូន្មាននរជនឲ្យរកសេពគប់មិត្តសំឡាញ់ ដោយទ្រង់សំដែងផលប្រយោជន៍នៃមិត្តសំឡាញ់ថា "អត្ថម្ហិ ជាតម្ហិ សុខា សហាយា មិត្តសំឡាញ់ទាំងឡាយអាចនាំសេចក្តីសុខមកឲ្យ ក្នុងពេលដែលសេចក្តីត្រូវការកើតឡើង" ដូច្នេះ ។

រាជា នោ សុខិតោ រជ្ជេ ហោន្តុ កម្ពោជិកា សុខី
រតនត្តយានុភាវេន យាចនំ ហោតុ និច្ចតំ

ទីបំផុតនៃព្រះធម្មទេសនានេះ សូមឲ្យព្រះរាជារបស់យើងទាំងឡាយគង់នៅជាសុខក្នុងរាជសម្បត្តិ, នឹងសូមឲ្យអ្នកកម្ពុជាទាំងអស់គ្នាបានសេចក្តីសុខ; ដោយអានុភាពនៃព្រះរតនត្រ័យ សូមឲ្យសេចក្តីបួងសួង (នេះ) បានសម្រេច (យ៉ាងឆាប់កុំខាន) ។

អាត្មាភាព សំដែងព្រះធម្មទេសនា អំពី "មិត្តកថា" ក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះឯង ឯវំ ។

---

របៀបទេសនាបុច្ឆា - វិសជ្ជនា

# ព្រះមហាឧត្តមវិជ្ជា កែ - អឿន (វីរិយប្បញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្រសៀមរាប រៀបរៀង

## ព្រះទេពសត្ថា ស៊ួរ - ហាយ ពិនិត្យកែសម្រួល

(តមក)

៩.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះត្រឹមត្រូវហើយ ៗ ចុះអ្នកណាខ្លះសមគួរជាទាយកធ្វើកឋិនទានបាន? សូមវិសជ្ជនាមកមើល ៗ

បពិត្រព្រះមហាថេរ! ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ ពោលតាមក្នុងគម្ពីរសមន្តបាឋថា យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្ដតិ

"ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ គឺ ទេវតាក្តី មនុស្សក្តី សហធម្មិកៈទាំង ៥ គឺ ភិក្ខុក្តី ភិក្ខុនីក្តី សាមណេរក្តី សាមណេរីក្តី សិក្ខមានាក្តី អ្នកទាំងអស់នេះ សមគួរជាទាយកធ្វើកឋិនទានបាន" សូមទានក្រាប ៗ -

១០.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ត្រូវហើយ ចុះកំណើតកឋិនទាន លោកអ្នកណាជាទាយកធ្វើជាដំបូង ក្នុងកាលដែលព្រះអង្គគង់

ជន្មាយុនៅបានធ្វើចំពោះព្រះសង្ឃក្នុងពេលនោះ? សូមលោកម្ចាស់សំដែងឲ្យជាក់ច្បាស់, ព្រោះរឿងនេះពុទ្ធបរិស័ទទាំងឡាយចង់ជ្រាបណាស់ ទឹងបានយកជាទិដ្ឋានុគតិ តទៅខាងមុខទៀត ។

- បពិត្រព្រះមហាថេរដ៏ចំរើន! ឯកំណើតកឋិនទានដែលទាយកផ្ដើមធ្វើជាដំបូងនោះគឺ "ព្រះបាទបសេនទិកោសល" ដូចមានរឿងដំណាលដោយសង្ខេបតទៅនេះ :-

កាលនោះព្រះបាទបសេនទិកោសល ព្រះអង្គបានតាក់តែងចាត់ចែងព្រះកឋិនទាន នាំទៅថ្វាយចំពោះព្រះភិក្ខុសង្ឃ មានអង្គព្រះកប្បាយ-នត្ថេរជាប្រធាន ។ ព្រះកប្បាយនត្ថេរទទួលគ្រងតាមគន្លងកឋិនត្ថារកិច្ចសម្រេចសព្វប្រការ, គ្រាកាលនោះព្រះបរមសាស្ដាចារ្យ ក៏ទ្រង់ត្រាស់ទេសនាសរសើរកុសលផលបុណ្យកឋិនទាន នៃព្រះបាទបសេនទិកោ-សលរាជ ដោយអនេកបរិយាយ ហើយទ្រង់ត្រាស់នាំអតីតនិទាននៃព្រះអង្គកាលអន្ទោលជាតិជា នរជីវទុគ្គតបរមពោធិសត្វ បានជួយខ្វល់ខ្វាយចាត់ការកឋិនទាននៃនាយកុដុម្ពិកនាំថ្វាយព្រះចមមុនី គឺព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គទ្រង់ប្រោសប្រទានឲ្យព្រះសុជាតត្ថេរជាអគ្គសាវកនៃព្រះអង្គគ្រងក្នុងគ្រានោះ. ឯអង្គព្រះបរមសាស្ដាជាម្ចាស់នៃយើងនេះ ព្រះអង្គក៏បានពុទ្ធព្យាករណ៍ទំនាយអំពីសំណាក់នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈអំពីកាលនោះមក លុះព្រះអង្គបានត្រាស់ហើយ

ទើបទ្រង់សំដែងព្រះសទ្ធម្មវិសេសទេសនា ប្រារព្ធនូវបុព្វចរិយានៃព្រះអង្គអំពីកាលព្រះអង្គកើតជា នរជីវទុគ្គតពោធិសត្វ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈមកនោះ ស្រេចហើយ ព្រះអង្គទ្រង់អនុញ្ញាតសំពត់កឋិនដល់ភិក្ខុទាំងឡាយ ដែលមានត្រៃចីវរទុព្វលភាព ហើយទ្រង់បញ្ញត្តនូវសិក្ខាបទ ដែលព្រះសង្គីតិកាចារ្យបានពោលទុកក្នុងគម្ពីរមហាវគ្គដោយពិស្តារ ហើយទ្រង់ទេសនាសរសើរផលានិសង្សនៃកឋិនទាននេះថា មានផលវិសេសលើសលន់ពន់ប្រមាណណាស់ ។

លំដាប់នោះមានព្រះថេរៈ ១ ព្រះអង្គ ព្រះនាមនារទត្ថេរបានស្តាប់ព្រះធម៌ទេសនាកឋិនានិសង្សដូច្នោះហើយ ទើបលោកមានហឫទ័យដ៏ពេញដោយបីតិជ្រះថ្លា គិតថា "កឋិនទានមានផលានិសង្សអស្ចារ្យយ៉ាងនេះ គួរអាត្មាអញនឹងសាងថ្វាយដល់ជំនុំសង្ឃម្តងចុះ"; កាលព្រះនារទត្ថេរលោកគិតដូច្នោះហើយ ទើបលោកដោះឡើងទៅកាន់ត្រកូលញាតិ ហើយលោកបបួលពពួកញាតិលោកឲ្យជួយក្នុងការកឋិនទាន លុះបានគ្រប់គ្រឿងកឋិនហើយ លោកនាំអង្គព្រះកឋិននោះទៅកាន់អារាមមួយអន្លើដោយពពួកញាតិជាបរិវារ ។ លុះបានដល់អារាមហើយព្រះនារទត្ថេរក៏យកសំពត់កឋិននោះ ដម្កល់ទៀបព្រះបាទយុគលនៃព្រះតថាគត ហើយសូត្រវេរថ្វាយដោយបាលីថា ភន្តេ ឥមានិ ចីវរានិ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស កឋិនត្ថាយ ទស្សាមិ ប្រែជាសេចក្តីថា

“បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាសូមថ្វាយនូវចីវរទាំងឡាយនេះដល់ព្រះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ដើម្បីក្រាលជាកឋិនក្នុងឆ្នាំនេះ” ។ គ្រាកាលនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គក៏ឲ្យប្រជុំភិក្ខុទាំងឡាយ ៥០០ រូប ហើយញ៉ាំងភិក្ខុទាំងឡាយមានការដេរនូវចីវរកឋិនជាដើមឲ្យសម្រេចសព្វគ្រប់ប្រការ កាលនោះឯង ។ សាធុពោ បពិត្រសាធុសប្បុរសទាំងឡាយ ! ឯកិរិយាដែលព្រះនាងទេវីធ្វើកឋិនដើម្បីភិក្ខុសង្ឃមានអង្គព្រះពុទ្ធជាប្រធាននោះ ក៏កើតជាអស្ចារ្យអស់ជំនុំសង្ឃសឹងនាំគ្នានិយាយសរសើរកុសលផលបុណ្យ នៃព្រះនាងទេវីជាអនេកបរិយាយ កាលនោះសម្ដេចព្រះឈ្នះមារក៏ទ្រង់ត្រាស់ប្រកាសនាំនូវអតីតនិទាននៃព្រះអង្គ កាលកើតជាស្ដេចបរមចក្កពត្រាធិរាជ ១ ព្រះអង្គទ្រង់ព្រះនាមព្រះបរមចក្កវិជិតរាជ ប្រកបដោយអំណាចជាធំក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ព្រះអង្គបានសាងកឋិនទាន ថ្វាយព្រះពុទ្ធទ្រង់ព្រះនាមព្រះកោណ្ឌញ្ញសម្មាសម្ពុទ្ធដែលត្រាស់ដឹងក្នុងសារកប្បជាកប្បក្នុងយូរទៅហើយនោះ នាំមកសំដែងជាសណ្ដាប់ប្រាប់ភិក្ខុទាំងឡាយ ក្នុងព្រះសាសនាដោយពិស្ដារជាអនេកបរិយាយ ។ ក្នុងទីនេះអាត្មាភាពសំដែងសេចក្ដីតែខ្លីៗ នាំមកឲ្យឃើញតួបុគ្គលអ្នកធ្វើគឺព្រះបាទបសេនទិកោសលរាជជាបច្ចុប្បន្ននិទាន ព្រះនរជីវទុគ្គតពោធិសត្វនឹងនាយកុដុម្ពិកនោះក្ដី ស្ដេចបរមចក្កវិជិតរាជនោះក្ដី ពីរនិទាននេះជា

អតីតនិទាន ចំណែកខាងព្រះសង្ឃអ្នកធ្វើសោត គឺព្រះនារទត្ថេរជាបច្ចុប្បន្ននិទាន, និទានព្រះនារទត្ថេរធ្វើកឋិននេះគួរយកជាបែបយ៉ាងបាន ហេតុនេះទើបឃើញបព្វជិតទាំងឡាយពីបុរាណធ្វើកឋិនតៗមក ព្រោះអាស្រ័យនិទានព្រះនារទត្ថេរនេះឯង; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបាននាំនិទាន មកដោយសង្ខេបតែប៉ុណ្ណោះ សូមទានជ្រាប ។

១១– កល្លោសិ អនុត្ថេរ: ម្នាលអនុត្ថេរ! លោកម្ចាស់ឆ្លៀវឆ្លាសវាងវៃមែន ចេះទាញនិទាននាំមកសំដែងប្រៀបប្រាយអធិប្បាយស្តាប់បានដោយងាយ លុះពុទ្ធបរិស័ទទាំងឡាយសន្និដ្ឋានចូលចិត្តយកជាបែបយ៉ាងបានហើយ, លំដាប់តពីនេះទៅខ្ញុំលើកយកប្រស្នាដទៃមកសួរតទៅទៀត ។ អើលោកម្ចាស់ កាលបើទាយកដង្ហែកឋិនចូលមកវេរចំពោះព្រះសង្ឃហើយ តើសង្ឃត្រូវទទួលដោយអាការដូចម្តេច? សូមលោកម្ចាស់វិសជ្ជនាមក ហើយអាងគម្ពីរផង ដើម្បីជាគោលចារិកមាំមួនតទៅ ។

(មានត)

## ការបណ្តុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

## យុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

## ឧបាយបណ្តុះនិស្ស័យទី ៦

# និស្ស័យរាប់អានគ្នា

*លោកអ្នកនិរភ័យទាំងឡាយ! លោកអ្នកបានជ្រាបពីខាងដើមរួចមក ហើយថា តាមគោលក្នុងច្បាប់សង្គមវិទ្យានោះ មនុស្សយើងរមែងជាសង្ឃក្កុតិ គឺជាសត្វស្រុកដែលត្រូវរួបរួមគ្នាជាពួក ចាប់ដើមតាំងអំពីជាគ្រួសារ ជាស្រុក ជាភូមិ រហូតដល់ជាប្រទេស. ទឹងត្រូវជាប់ទាក់ទងគ្នា ក្នុងការបន្តសមាគម ទឹងទៅបែកខ្ញែកគ្នារាត់រាយដោយមិនរួមគ្នា ឬមិនជាប់ទាក់ទងគ្នាមិនបាន ។ សូម្បីក្នុងប្រវត្តិសាស្ត្រក៏ត្រូវជាប់គ្នាដោយខ្សែលោហិត ឬផៅពង្សពន្ធុ ទឹងត្រូវជាប់តខ្សែលោហិតគ្នាមក ដោយលទ្ធិប្រវេណី ឬទំនៀមទំលាប់ដែលត្រូវតែនៅរួមគ្នាជាពួកគណៈ ដែលហៅថា "ជាតិ" សូម្បីទឹងបែកខ្ញែកគ្នាចេញទៅនៅឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ ក៏លក្ខណៈពណ៌សម្បុរទឹងភាសាសំដីនិយាយសំដែងឲ្យឃើញថាជាខ្សែជាតិជាមួយគ្នាដែរ ។*

មនុស្សយើង សូម្បីជាប់គ្នាដោយខ្សែលោហិតនឹងជាប់ខ្សែគ្នាមកដោយលក្ខិប្រវេណី ដែលអាចរាប់ថាជាខ្សែលោហិតជាមួយគ្នាដូចពោលមកហើយក៏ដោយ ក៏គប្បីប្រាប់ ១ ជាន់ទៀតថា ការនៅរួមគ្នានៃមនុស្សពួកច្រើននោះ រមែងធ្វើឲ្យកើតហេតុការណ៍ នឹងបណ្ដាលឲ្យកើតសុខ, ទុក្ខ, ចំរើនវិនាសឡើង ដល់គ្នានឹងគ្នាបាន ៗ បើមនុស្សមានសីលធម៌ ចេះរាប់អានស្រឡាញ់គោរពកោតក្រែងចិត្តគ្នា មើលឃើញដំខ្សែនៃភាពជាមនុស្សដូចគ្នា មិនភ្លេចថា "យើងជាមនុស្ស ឯអ្នកដទៃក៏ជាមនុស្សដែរ" មានមេត្រីចិត្តមិត្តភាព មានកិរិយានឹងវាចាសុភាពទន់លំទោនចំពោះគ្នា លើកដំកើងសរសើរនឹងជួយអនុគ្រោះចំពោះគ្នានឹងគ្នាហើយ រមែងបង្កឲ្យកើតសន្តិសុខនឹងសេចក្ដីចំរើនថិតថេរស្ថាពរឡើងដល់គ្នានឹងគ្នា ៗ តែបើជាមនុស្សគ្មានសីលធម៌ មិនចេះរាប់អានលើកដំកើងសរសើរគ្នា សំដែងអាកាលុបគុណមើលងាយគ្នា ធ្វើសេចក្ដីអាក្រក់ ចង្រៃពោរពេញប្រទូសរ៉ាយ កាចសាហាវចំពោះគ្នា ប្រាថ្នាយកប្រៀបគ្នា ប្រថ្នាប្រៀតប្រៀនសង្កត់សង្កិនខាំសាច់គ្នាស៊ីដូចសត្វព្រៃវិញ ក៏មុខជាត្រូវបំពេញទុក្ខភ័យក្ដៅក្រហាយឲ្យដល់គ្នានឹងគ្នា ៗ

ពិតមែន ស្រុកណា ផ្ទះណា ដែលមានសេចក្ដីរាប់អានស្រឡាញ់គ្នា ចូលទៅតាំងនៅជានាយចៅហ្វាយហើយ ស្រុកនោះ ផ្ទះនោះរមែងជាទីនៅដ៏សុខសម្រាន្ត ធ្វើឲ្យកើតពន្លឺស្វាងរុងរឿងរីករាយសប្បាយស្រស់

ស្រាយរីកមុខរកគ្នា ៗ បើយើងបានទៅក្នុងស្រុកភូមិដូច្នោះ ប៉ុនគ្នានឹងបាននៅក្រោមដើមឈើដែលមានម្លប់ត្រជាក់ មានហ្វូងសត្វស្វាបបោមពេមហិចហើរទៅមក មានសូរសៀងនិយាយគ្នាលេងល្ហើយ នឹងបញ្ចុកអាហារគ្នា ជាទីគួរឲ្យកើតកើនចិត្តយ៉ាងក្រៃលែង ៗ ដូច្នេះ ដើម្បីនឹងឲ្យការនៅរួមគ្នានឹងការជាប់ទាក់ទងគ្នាបានសន្តិសុខ នឹងវឌ្ឍនាការស្ថាពរ យើងទើបគួរបណ្តុះនិស្ស័យរាប់អានគ្នាតាមថ្នាក់ជាញាតិមិត្ត នឹងជាអ្នកធំអ្នកតូច ឬ អ្នកស្មើគ្នា ៗ ការសំដែងកាយរាប់ជាសុភាពនុនលំទោន. បំពោះគ្នា ប្រព្រឹត្តខ្លួនស្មោះស្មើ លើកដំកើង បរសើរគ្នាតាមទំនងដែលគួរ នឹងអើពើជឿស្តាប់គ្នានេះ ជាលក្ខណៈនៃសេចក្តីរាប់អានគ្នា ៗ បើលោក-អ្នកសំដែងកាយរាប់ជាសុភាពនុនលំទោនបំពោះគ្នា ប្រព្រឹត្តខ្លួនឲ្យស្មោះស្មើ លើកដំកើងសរសើរស្តាប់បង្គាប់គ្នាតាមឋានៈអ្នកធំនឹងអ្នកតូចរហូតទៅជាអាចិណ្ណវត្ត ដក់ជាប់នៅក្នុងសន្តានហើយ លោក-អ្នកបានឈ្មោះថា ជាអ្នកមាននិស្ស័យរាប់អានគ្នា ៗ

លោក-អ្នកគង់ធ្លាប់បានឃើញហើយ . មនុស្សខ្លះចូលចិត្តនៅសៀម ៗ បែរខ្នងឲ្យគេ មិនអើពើរមើល-ស្តាប់ក្នុងកាលដែលមានគេនិយាយជាមួយ, មនុស្សខ្លះធ្វើកុងកាំងនាំឲ្យជាទីរំខានចិត្តដល់អ្នកដទៃ បើអង្គុយឬឈរទទឹងផ្លូវនរណា កំធ្វើព្រងើយកន្តើយ. មិនចៀសផ្លូវឲ្យអ្នកនោះ ខ្លះដើរជិតឬឈររជិតអ្នកដែលអង្គុយ កំដើរបែបចង់កន្លងសីស:

(ក្បាល) ឬដើរជិតសីសៈ ឬក៏ឈរបែបចង់ជាន់សីសៈ តុំនោះឈរប្រត់សីសៈ ខ្វះក៏ក្រោកវែកគេចេញទៅដោយមិនបានសូមទោសគេ កាលបើមានភ្ញៀវទៅណាមកណា ក៏មិនក្រោកទៅទទួល-ទៅអញ្ជើញ ឬស្រស់ស្រាយប្រស្រ័យដោយរាក់ទាក់ ៗ នរណានិយាយអ្វីក៏ចោទប្រកាន់ ចាប់ថ្នាក់គេ មិនថាខុស ឬត្រូវឡើយ ជាមនុស្សរើសរូស ប្រមាថមើលងាយមនុស្សដទៃ ឃើញថាគេសុទ្ធតែអន់ជាងខ្លួនទាំងអស់ មិនទុកដាក់កិរិយាអធ្យាស្រ័យតាមដែលសមដែលគួរ ជាមនុស្សលុបគុណវាយឫក លើកដំកើងខ្លួនដើម្បីសង្កត់អ្នកដទៃដោយចូលចិត្តថាជាគ្រឿងធ្វើឲ្យគេបោកទាប ហើយឋានៈរបស់ខ្លួនក៏នឹងខ្ពស់ត្រដែតឡើង វាយឫកដោយនឹកសំគាល់ក្នុងចិត្តថាខ្លួនជាមនុស្សល្អ ជាមនុស្សសំខាន់ មិនមានសម្មាគារវៈចំពោះនរណាមួយ ទំដំឡើងអំណាច ដំឡើងធ្ងន់ដោយយល់ថាខ្លួនជាអ្នកធំ ជាមនុស្សខ្ពង់ខ្ពស់ថ្កើងយសថ្កើងស័ក្តិ ចិត្តរឹងត្អឹងរឹងរូស យោះយៅយង់ឃ្នងប្រះដាក្រ មិនព្រមជឿមិនព្រមស្តាប់ពាក្យចាស់គៀនណែនាំទូន្មាន រៀនប្រដៅរបស់នរណាទាំងអស់នេះ ឈ្មោះថាជាមនុស្សមិនរាប់អានអ្នកដទៃ ៗ

សេចក្តីអាក្រក់ទាំងនេះ ជាទីគួរឲ្យខ្មាសកែលែង ៗ សូម្បីត្រឹមតែនិយាយអាក្រក់ចំពោះគ្នាប៉ុណ្ណោះ ប្រសិនបើគិតមើលតែស៊ើរៗ រាក់ៗ ក៏ឃើញថា ហាក់ដូចជាការបន្តិចបន្តួចសោះ តែកាលបើពិគ្រោះឲ្យល្អិត

ល្អន់ទៅ គង់នឹងឃើញថាជាទោសដ៏ធំក្រៃលែង ៗ បើលោក-អ្នកព្រម បណ្ដោយឲ្យអំពើបែបនេះ ចូលមកគ្របសង្កត់ចិត្តទាល់តែស៊ប់ស្ងួនហើយ លោក-អ្នកក៏នឹងទៅជាសត្វយ៉ាងកាចសាហាវ ព្រោះនឹងធ្វើដំណឹង (សេចក្ដីដឹង) ខាងក្នុងរបស់លោក-អ្នកឲ្យអាក្រក់រឹងរូសទៅតាមកិរិយា ខាងក្រៅ ចាំងបំផ្លាញភាពជាមនុស្សល្អឲ្យអស់ទៅផង ខ្លួនលោក-អ្នក ក៏នឹងក្លាយទៅជាមនុស្សមាននិស្ស័យអាក្រក់ គ្រោតគ្រាតរឹងរូសលុប គុណមើលងាយអ្នកដទៃ ៗ ដូច្នេះ ការសំដែងកាយវាចាគ្រោតគ្រាត ទើបចាត់ថាជាគ្រឿងសំគាល់នៃការមិនរាប់អានគ្នា ៗ

មនុស្សមាននិស្ស័យមិនរាប់អានអ្នកដទៃ សូម្បីនៅក្នុងទីណា ក៏មាន តែការបង្កសេចក្ដីក្រោធឲ្យកើតឡើងដល់គ្នានឹងគ្នាក្នុងទីនោះ ដូចជាកាល សំដែងសេចក្ដីអាក្រក់ចំពោះអ្នកណា អ្នកនោះរមែងក្រោធមិនពេញចិត្ត ហើយនឹងស្អប់ខ្ពើម បើខំបញ្ចេញចំពោះមនុស្សដទៃច្រើនគ្នាផង ក៏រឹង រឹតតែបន្ថែមចំនួនមនុស្សដែលក្រោធខឹងស្អប់ខ្ពើមច្រើនឡើងដែរ ឥតមាន អ្នកល្អណាមួយ ប្រាថ្នាសមាគមសេពគប់រកឡើយ ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៦

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ឯទាហានគៀវស៊ីវដែលពួនបង្កប់នៅទីនោះ ក៏អុចផាវបោះឡើងជាសញ្ញា ហើយនាំគ្នាចេញស្រែកទាំងសងខាង ព្រួតគ្នាវាយខ្ទប់ចាប់កាប់សម្លាប់កងទ័ពចូចូស្លាប់ផាសជាច្រើនណាស់ នៅសល់រួចប៉ុន្មានក៏ទទ្រានស្ទុះរត់រួចថយចេញទៅក្រោយ ។ គៀវស៊ីវក៏បរពលដេញបណ្ដោយទៅ ។ ឯចូចូនឹងបណ្ដាទាហាន ដែលនៅរក្សាបន្ទាយក៏ភ្លយបែកខ្ញែកទៅជាមួយគ្នា ។ គៀវស៊ីវក៏ដេញបំពារទៅទៀតបានចម្ងាយប្រហែល ៣០០ សិន (១២ គ.ម.) ជួនក្លីស្រាង គៀវស៊ីវក៏នាំទាហានវិលចូលមកស្រុកវិញ ។

ចូឆូឃើញអ៊ីគឹមទឹងល័យ៉យត្រូវព្រួញជាច្រើនអន្ទើ   ក៏ឲ្យត្រួតពលទាហានមើលឃើញបាត់ប្រហែល ៥ ម៉ឺននាយ ។ កាសៀងដឹងថាចូឆូខូចខាតទាហានជាច្រើន  ក៏និយាយនឹងគៀវស៊ីវថា  សុំឲ្យលោកមានសំបុត្រទៅដល់ឡេវពៀវនៅស្រុកកេងជីវ  ឲ្យឡេវពៀវទៅចាំស្ទាក់វាយចូឆូ  ឃើញថានឹងចាប់ខ្លួនចូឆូបាន ។ គៀវស៊ីឃើញត្រូវ  ទើបតែងសំបុត្រផ្ញើទៅឲ្យឡេវពៀវ ។

ឡេវពៀវបានទទួលសំបុត្រដឹងសេចក្ដីហើយ  ក៏ប្រមូលសេនាទាហាននឹងលើកទៅចាំស្កាត់ចូឆូ  ទទួលដឹងដំណឹងថា  ស៊ុនសិកលើកទ័ពទូកមកតាំងនៅបាក់អាវស្រុកកេងជីវ ។ ឡេវពៀវទើបប្រឹក្សានឹងកេង-លៀងថា  គៀវស៊ីវមានសំបុត្រមកដល់យើង  ឲ្យលើកទ័ពទៅស្ទាក់វាយទ័ពចូឆូ  ឥឡូវស៊ុនសិកក៏លើកទ័ពមកគិតនឹងវាយយកស្រុកយើងៗ នឹងគិតប្រការដូចម្ដេចទៅវិញ ។ កេងលៀងឆ្លើយថា  ដែលស៊ុនសិកលើកមកគ្រានេះ  ជាគំនិតរបស់ចូឆូ  ឥឡូវចូឆូបរាជ័យនឹងចូវដេគៀវស៊ីវហើយ  មុខជាស៊ុនសិកធ្វើការមិនសម្រេច  យើងនឹងលើកទ័ពទៅវាយបន្ថែមឲ្យចូឆូបែកទ័ពចាញ់យើងឲ្យបាន  ទើបមិនកើតមានសេចក្ដីអន្តរាយដល់យើងខាងក្រោយ ។ ឡេវពៀវយល់ឃើញត្រូវក៏ចាត់ប្រើហងចលើកទាហានទៅស្ទាក់បង្ខំទ័ពស៊ុនសិកកុំឲ្យចូលមកបាន ។ ឡេវពៀវក៏លើកទ័ពទៅចាំស្ទាក់ទ័ពចូឆូនៅដែនស្រុកអានបុងគួន ។

តៀវស៊ីវកាលផ្ញើសំបុត្រទៅឲ្យឡ្យាពៀវហើយ ក៏ចាត់ទាហានលើកទ័ពតាមចូឆូទៅ ៗ កាលដែលចូឆូបែកទ័ពទៅនោះ មិនបានឲ្យទាហានស្រូតរូតប្រញាប់ លើកទ័ពលំហែទៅតាមផ្លូវជាប្រក្រតី លុះទៅដល់ទន្លេយ៉ុកស៊ុយ ចូឆូក្លែងធ្វើជាយំសោក ៗ ទាហានទាំងពួងឃើញដូច្នោះ ក៏ជំរាបសួរចូឆូថា លោកយំសោកជាទុក្ខព្រោះហេតុអ្វី? ៗ ចូឆូឆ្លើយថា យើងមកដល់ទីនេះ. ឲ្យបេះតែមានចិត្តគិតនឹករលឹកដល់តៀនអ៊ុយ ដែលស្លាប់ ព្រោះធ្លាប់មកជាមួយគ្នាជាមិត្រភក្តិកំសត់កម្រ" ហើយក៏ឲ្យតែងតាំងគ្រឿងសក្ការៈអុចធូបទៀនដូចស្រាសែនឲ្យតៀនអ៊ុយ ៗ ទាហានទាំងពួងក៏យំសោកទាំងអស់គ្នា ហើយចូឆូក៏សែនឲ្យបោសាំងជាកូន និងបោអាន់ប៊ុនជាក្មួយ ហើយនឹងបណ្តាកូនទាហាន ដែលស្លាប់ទាំងប៉ុន្មាន ហើយលើកទាហានឆ្លងទន្លេយ៉ុកស៊ុយទៅ ៗ ទទួលមានបំរើសេះនាំសំបុត្រស៊ុនហុកមកជូនចូឆូៗ មើលសេចក្តីដឹងថា តៀវស៊ីវឲ្យឡ្យាពៀវលើកកងទ័ពមកស្ទាក់នៅដែនស្រុកអាន់ប៊ុងគួន ឲ្យលោកគិតការពារប្រយ័ត្នឲ្យមាំមួន ៗ ចូឆូក៏ធ្វើសំបុត្រតបទៅឲ្យស៊ុនហុកថា "ដែលឡ្យាពៀវលើកទ័ពមកស្ទាក់ផ្លូវទុកនោះ ហើយតៀវស៊ីវលើកទ័ពតាមមកពីក្រោយ យើងដឹងអស់ហើយ បានជាយើងដើរទ័ពលំហែតែ ១ ថ្ងៃ ១០០ សិន (៤ គ.ម.) ដើម្បីនឹងគិតជាកលឧបាយបញ្ឆោតតៀវស៊ីវ និងឡ្យាពៀវឲ្យមានចិត្តកំរើបធ្វេសប្រហែស យើងនឹងវាយយកជ័យជំនះឲ្យបាន ដែល

ស៊ិនហ៊ុករំលឹកស្មារតីយើងនោះ យើងក៏អរគុណណាស់ហើយ កុំឲ្យស៊ិន-ហ៊ុកវិតក្កឡើយ" ដូច្នេះហើយលើកទ័ពទៅជិតនឹងដល់ស្រុកអាទប៊ុងគួន ឮកិត្តិស័ព្ទថាកងទ័ពតៀវស៊ីវលើកជិតទាន់ហើយ ។ លុះដល់ពេលព្រលប់ ប៊ុចឆូក៏បង្គាប់ទាហានឲ្យញែកគ្នាជា ២ កង ឲ្យដឹករំលុងពួនខ្លះ ពួនក្នុងគុម្ពោតព្រៃឈើខ្លះ ពួនក្នុងគុម្ពសៅ តាំងសងខាងផ្លូវខ្លះ ចម្ងាយប្រហែល ៩-១០ ស៊ិន (៤០០ម.) ហើយឲ្យតាំងបន្ទាយអែបទៅខាងក្នុងក្បែរផ្លូវខ្លះ ឲ្យទា-ហាននៅរក្សាបន្ទាយតិចល្មមសមគួរ បើឃើញទ័ពតៀវស៊ីវតាមមកដល់ឲ្យទាហានក្នុងបន្ទាយសម្ងំឲ្យស្ងៀម ទាល់តែតៀវស៊ីវលើកចូលវាយបន្ទាយគ្រាណា ឲ្យអុចផាវជាសញ្ញាឡើង ឲ្យទាហានទាំង ២ កងលើកចេញមកខ្ទប់តាំងសងខាង ឯតៀវស៊ីវក៏បង្ខំលើកទ័ពទៅទាំងយប់ មិនទាន់ឃើញបន្ទាយដែលប៊ុចឆូតាំងទុក ក៏លើកទាហានបង្ហួសចូលទៅជួបកងទ័ពឡៅតៀវ ហើយសួរថា បានជួបនឹងកងទ័ពប៊ុចឆូឬទេ? ។ ឡៅតៀវឆ្លើយថា មិនបានជួបប្រទះទេ ។ លុះព្រឹកឡើងទាហានជំរាបតៀវស៊ីវថា ប៊ុចឆូតាំងបន្ទាយនៅក្បែរនឹងជើងភ្នំខាងក្រោយ ឃើញទាហានក្នុងបន្ទាយមានស្តួចស្តើងទេ ។ តៀវស៊ីវនឹងឡៅតៀវអរណាស់ ទើបលើកទ័ពប្រសព្វគ្នាទាំងសងខាងរួមជាកង ១ ហើយក៏លើកចោមវាយទំលាយបន្ទាយប៊ុចឆូទាំងថ្ងៃ ។

ប៊ុចឆូក៏អុចផាវជាសញ្ញាឡើង, ឯទាហានដែលបង្កប់តាំងសងខាងផ្លូវក៏លើកចេញស្រមកវាយខ្ទប់ប្រសព្វគ្នា កាប់សម្លាប់ទ័ពតៀវស៊ីវនឹងឡៅ

ពៀវស្លាប់ជាច្រើន ។ តៀវស៊ីវនឹងឡេវពៀវក៏បែករត់ទៅ ចូចូក៏លើកទាហានស្រូតទៅតាល់តែផុតដែនស្រុកអាន់ចុងគួន ទើបតាំងបន្ទាយនៅទីនោះ ។ ឡេវពៀវនិយាយនឹងតៀវស៊ីវថា ពេលនេះយើងចាញ់កលចូចូដោយដឹងកលមិនដល់ ។ តៀវស៊ីវឆ្លើយថា ឥឡូវទាហានយើងនៅកំពុងហត់នឿយណាស់ ត្រូវតែសម្រាកឈប់ឲ្យទាហានមានកំឡាំងកាលណា នឹងគិតការសងសឹកចូចូឲ្យបានវិញ ។ ឡេវពៀវយល់ឃើញត្រូវ ក៏ឲ្យតាំងបន្ទាយនៅក្នុងទីនោះ ។

ឯស៊ុនហុកដែលនៅរក្សាស្រុកដល់ដឹងក្នុងសំបុត្រចូចូហើយ ទទួលឮកិត្តិស័ព្ទថា អ៊ួនសៀវនឹងលើកទ័ពទៅវាយស្រុកហ៊ូតោ ក៏ធ្វើសំបុត្រប្តឹងមកចូចូតាមដំណើរហេតុនោះ ។ ចូចូឮដូច្នោះក៏ទោមនស្សតូចចិត្តពេក ទើបប្រមូលសេនាទាហានស្រូតលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោ ។ ឯតៀវស៊ីវឮថា ចូចូលើកកងទ័ពត្រឡប់ទៅស្រុកហ៊ូតោហើយ ក៏រៀបប្រមូលសេនាទាហានលើកទៅតាមចូចូ ។ កាសៀងនិយាយហាមឃាត់ថា ដែលលោកនឹងលើកទៅតាមលើកនេះ ខ្ញុំយល់ឃើញថា គង់ចាញ់គេជាអសារឥតការ ។ ឡេវពៀវឆ្លើយថា ពេលនេះបានការល្អហើយ នឹងមិនលើកតាមទៅ ចុះនឹងនៅធ្វើអ្វីឲ្យព្រួយការ ។

(មានត)

# រឿងអាក័ក្សថ្លែងរឿងម្ភៃប្រាំ

## លោករ៉ាយ-ប៊ុក ក្រមការ

ប្រែពីបារាំងមកជាខ្មែរ

(តមក)

## រឿងទីដប់ប្រាំបី

អារក្សក្រាបបង្គំទូលថា: បពិត្រមហារាជ! មាននគរមួយឈ្មោះ កុពលបុរ: (Kubalpur ប្រែហលជា កមលបុរ: ប្រែថា នគរកមល, នគរផ្កាឈូក) ។ ព្រះមហាក្សត្រដែលសោយរាជ្យនៅនគរនោះ ទ្រង់ព្រះនាមសុទក្សិ (Sudakshi) ។ នៅក្នុងនគរនោះ មានពាណិជម្នាក់ឈ្មោះ ធនក្សិ (Dhanaskhi) គាត់មានបុត្រីម្នាក់នាមនាងធនវតី (Dhanvati) ។ នាយពាណិជបានរៀបចំទូវវិវាហមង្គលការ នាងទៅនឹងប្រុសកម្លោះម្នាក់ ឈ្មោះគូរីទត្ត (Gauridatt) តាំងពីយុវវ័យ ។ ឯគូស្វាមីភរិយានេះ បានបុត្រីម្នាក់នាមនាងមោហនី (Mohani) ។ ប៉ុន្មានឆ្នាំក្រោយមកគូរីទត្ត ទទួលអនិច្ចកម្ម ។ ញាតិសន្តានខាងស្វាមីនាងធនវតី បានដណ្ដើមយកទ្រព្យសម្បត្តិពីនាងអស់គ្មានសល់ ។ នាងគ្មានធនធាន, បានដឹកដៃបុត្រីនាង ដើរចេញពីគេហដ្ឋានរបស់នាងក្នុងពេលយប់ងងឹត ធ្វើដំណើរទៅកាន់គ្រឹហាបិតាមាតា ។ ដល់នាងត្រាច់តាមផ្លូវនាងវង្វេងផ្លូវ, បានទៅដល់ចួបដ្ឋានមួយដែលគេកំពុងធ្វើទណ្ឌកម្មចោរម្នាក់ ដោយយក

ឈើស្រួចមួយបុកពីទ្វារធំចូលទៅក្នុងពោះវៀន តែចោរនោះនៅរស់នៅឡើយ ។ ក្នុងពេលនោះយប់ងងឹត នាងធនវតីបានប៉ះជើងចោរនោះនឹងដៃនាង ។ ចោរនោះក៏ស្រែកថា: “នាងឯងធ្វើឲ្យយើងឈឺពន់ពេកណាស់” ។

នាងធនវតីតបថា: “ខ្ញុំគ្មានបំណងនឹងធ្វើឲ្យអ្នកឈឺចាប់សោះឡើយ, សូមអ្នកអត់ទោសខ្ញុំចុះ” ។

ចោរពោលថា: “នៅស្ថាននេះគ្មានអ្នកណាឲ្យទុក្ខឬឲ្យសុខទេ ។ គេទទួលតែទុក្ខ ដែលព្រះអាទិទេពបានកត់ក្នុងជោគវាសនា ហើយអ្នកផងពោលថា យើងបានធ្វើនេះឬបានធ្វើនោះជាអ្នកខ្លៅល្ងង់, ព្រោះថាមនុស្សមានខ្សែជោគវាសនាចាក់ចង ។ ខ្សែនោះដឹកនាំអ្នកពីទីនេះទៅទីនោះ ។ គ្មានអ្នកណាអាចយល់ព្រះរាជបំណងនៃព្រះអាទិទេពទេ ។ មនុស្សកាត់ខ្សែបំណងនេះ តែងធ្វើខ្សែបំណងជាថ្មីមួយទៀតមិនចេះអស់មិនចេះហើយ” ។

នាងធនវតីបានស្ដាប់វាចារបស់ចោរក៏សួរថា ‘អ្នកជាអ្វី?” ។ ចោរក៏តបទៅនាងវិញថា “ខ្ញុំជាចោរ, ខ្ញុំបានទទួលទុក្ខកម្មនេះបីថ្ងៃហើយតែខ្ញុំនៅតែមានជីវិតនៅឡើយ” ។ នាងក៏សួរទៅវិញថា “ព្រោះហេតុអ្វី?” ។

– ព្រោះខ្ញុំមិនទាន់មានប្រពន្ធនៅឡើយ ចូរនាងឲ្យបុត្រីនាងមកជាប្រពន្ធខ្ញុំ ហើយខ្ញុំនឹងជូននាងនូវរូបិយអាស្សរហ្វី (Assrahi រូបិយមាសតម្លៃ ៤០ ត្រណោត) ចំនួនមួយក្រោ (Crore ou Karôr គឺ ១ លាន អាស្សរហ្វី) ។

ពិតមែនតែចិត្តកំណាញ់ជាឫសគល់នៃបាបធម៌ តណ្ហាជាហេតុឲ្យកើតទុក្ខ ព្រោះថាក់ជាប្រភពនៃសេចក្ដីលំបាក ។ បើអ្នកណាការពារកុំឲ្យសភាពទាំងពីរនេះកើតឡើងបាន, អ្នកនោះអាចរស់នៅជាសុខក្នុងលោក ។ តែអ្នកទាំងអស់ពៀសវៀងនូវសភាពទាំងពីរនេះមិនផុត ។ ចិត្តកំណាញ់ចូលទៅទាក់ចិត្តនាងធនវតីក្នុងពេលនោះ ។ នាងក៏បានប្រគល់បុត្រីទៅឲ្យចោរហើយសួរថា "តើអ្នកមានមធ្យោបាយយ៉ាងណាឲ្យកូនប្រុសមួយបដិសន្ធិក្នុងគេហដ្ឋានបាន?" ។

ចោរពោលថា "កាលណាបុត្រីនាងនឹងទៅជាករិយាគេទៅអនាគត, នាងត្រូវហៅព្រហ្មណ៍ស្អាតម្នាក់, ហើយក៏ឲ្យបុត្រីនាងព្រមទាំងប្រាំរយមុហារ្ស (muhars រូបិយមាស) ហើយនាងជាបុត្រីមុខជាប្រសូតិកូនប្រុសមួយមិនខាន" ។

ដល់នាងធនវតីបានស្ដាប់ពាក្យចោរហើយ, នាងក៏បានដឹកដៃកូនស្រីប្រទក្សិណឈើស្រួចបោះជាប់នោះបួនជុំ, ហើយប្រគល់កូនស្រីនាងឲ្យទៅចោរធ្វើជាប្រពន្ធ ។ ចោរក៏ពោលថាៈ "ខាងកើត, នៅជិតអណ្ដូងគង្គា មានដើមអជបាលនិគ្រោធមួយដើម ។ នៅទីនេះខ្ញុំបានយករូបិយមាសទៅកប់ទុកប្អូននាងអញ្ជើញទៅយកចុះ" ។ ចោរនោះពោលរួចហើយក៏ទទួលមរណភាពក្នុងពេលនោះ ។ នាងធនវតីបានទៅដល់ទីកន្លែងដែលចោរនោះប្រាប់ នាងបានយករូបិយមាសនោះទៅជូនបិតាមាតា ។

នាងបានថ្លែងនូវរឿងរ៉ាវជំរាបបិតាមាតាសព្វគ្រប់, នាងក៏អញ្ជើញបិតាមាតាទៅនៅឯភូមិដែលស្វាមីនាងនៅ ។ នាងបានចាត់ឲ្យសង់គេហដ្ឋានមួយធំហើយក៏នៅក្នុងទី នោះ ។ បុត្រីរបស់នាងក៏ចំរើនវ័យរៀវឆ្លានាការ រហូតដល់តរុណវ័យក្នុងពេលនោះ នាងក៏កំពុងអង្គុយលេងលើពនហាលជាមួយសហជីវិនីរបស់នាងម្នាក់, ស្រាប់តែនាងក្រឡេកទៅឃើញព្រាហ្មណ៍ជំទង់ម្នាក់ ត្រាច់តាមថ្នល់, នាងក៏មានចិត្តប្រតិព័ទ្ធស្នេហាទៅរកព្រាហ្មណ៍នោះ ។ ហើយនាងក៏បានពឹងមេនំម្នាក់ឲ្យជូនព្រាហ្មណ៍នោះទៅជិតមាតា ។ មេនំក៏ធ្វើតាមបង្គាប់នាង ។ មាតានាងដល់បានឃើញព្រាហ្មណ៍ជំទង់នោះក៏ពោលថា: "ឱព្រាហ្មណ៍! កូនស្រីខ្ញុំពេញក្រមុំហើយ, ចូរព្រាហ្មណ៍នៅជាមួយនឹងកូនស្រីខ្ញុំចុះ ដើម្បីនឹងឲ្យនាងមានកូនប្រុសមួយតពូជវង្សត្រទៅ ។ ខ្ញុំជូនអ្នកនូវមួយរយរូបិយមាស" ។

ព្រាហ្មណ៍នោះក៏ព្រមទទួលទាំងអស់ ។ អ្នកទាំងពីរក៏ពុងតែសន្និនាគ្នាទៅវិញទៅមក, ទទួលយប់មកដល់ ។ នាងក៏យកបហ្វបអាហារមកជូនស្វាមីពីសារ ។

សុភាសិតមួយពោលថា: តណ្ហាកើតឡើងដោយហេតុ ៧ យ៉ាងគឺ គ្រឿងក្រអូប, ស្ត្រី, សំលៀកបំពាក់, ម្លូ, ម្ហូបអាហារ, គ្រែនិទ្រា នឹងគ្រឿងអលង្ការផ្សេងៗ ។

ដល់នាងនឹងស្វាមីបានស្ថិតនៅជាមួយគ្នាមួយយប់ក្នុងបន្ទប់ គ្រែក្រអាលសប្បាយនូវកាមតណ្ហាតាមចិត្ត, លុះព្រឹកឡើង-ព្រាហ្មណ៍នោះ

វិលត្រឡប់ទៅផ្ទះវិញ ។ ឯនាងក៏មកអង្គុយជិតពួកសហជីវិនីរបស់នាងដូចដើម ។ មានសហជីវិនីនាងម្នាក់សួរនាងថា: "នាងដែលស្ថិតនៅជាមួយមិត្តនាងយប់មិញ តើមានចិត្តសប្បាយរីករាយយ៉ាងណាខ្លះ?" ។

នាងក៏តបវិញថា: "កាលខ្ញុំអង្គុយនៅជិតព្រាហ្មណ៍នោះ ខ្ញុំមានមនោសញ្ចេតនាព្រឺពោមព្រឺស្បែកជាបឋម, លុះដល់ព្រាហ្មណ៍ញញឹមមករកខ្ញុំហើយកាន់ដៃខ្ញុំៗ មានចិត្តទោរទន់ហើយខ្ញុំដឹងខ្លួនខ្ញុំថាខ្ញុំធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃព្រាហ្មណ៍គឺខ្ញុំបាញ់, ព្រាហ្មណ៍នោះ នៅជាម្ចាស់ចៅហ្វាយខ្ញុំ, តមកខ្ញុំភ្លេកស្មារតីមិនដឹងអ្វីទៀតសោះឡើយ" ។

គេពោលថា: ស្ត្រីមិនដែលក្បត់ស្វាមីឧត្តម, ក្លាហាន, មានប្រាជ្ញា, ជាចៅហ្វាយ, មានចិត្តសប្បុរស, មានគុណធម៌ឧបត្ថម្ភស្ត្រីគ្រប់យ៉ាងក្នុងជីវភាពបច្ចុប្បន្ននិងអនាគត ។

ក្នុងពេលនោះ នាងមោហនីមានគភ៌ លុះដល់គ្រប់ទសមាសនាងប្រសូតបុត្រមួយ ។ ដល់យប់ទី ៦ នាងប្រសូតបុត្ររួចស្រេច, នាងបានយល់សប្តិឃើញព្រះយាគីម្នាក់ មានសក់ក្រងដូចជាកន្ទេលលើក្បាល; នៅលើថ្ងាសមានរូបព្រះចន្ទភ្លឺចែងចាំង កាយលោកលាបដោយផេះនៃលាមកគោញីដែលគេយកទៅដុតហើយ ពាក់ខ្សែពិសិដ្ឋពណ៌សរបស់ព្រាហ្មណ៍ ព្រះយោគីនោះអង្គុយនៅលើអាសនៈធ្វើនឹងបុប្ផាបទុមសមានពាក់កងក ១ ធ្វើនឹងពស់សនឹងកងក ១ ទៀត ធ្វើនឹងក្បាលសាកសពដៃមួយកាន់រលាក្បាលសាកសព, ដៃមួយទៀត កាន់គ្រឿងដែកមាន

ធ្មេញបី ៗ លោកបានបង្ហាញរូបនិមិត្ត ចំពោះមុខនាងមានសភាពសំបើមអស្ចារ្យហើយពោលថា: "ស្អែកពេលពាក់កណ្ដាលអធ្រាត្រស្ងាត់ ចូរយកល្អីមួយធំដាក់រូបិយមាស ១.០០០ មុហារ្យ. ព្រមទាំងបុត្រកូននោះផងរួចយកទៅបោះបង់ចោលមុខក្លោងទ្វារព្រះបរមរាជវាំង" ។ ដល់នាងស្ដាប់ពាក្យព្រះយោគីក្នុងនិមិត្តនោះ នាងក៏ភ្ញាក់ពីនិទ្រា, បើកភ្នែក, លុះព្រឹកឡើង, បានទៅពណ៌នារឿងយល់សប្ដិនោះ ជំពបនាងធនវតីជាមាតា ។ នាងជាមាតាបានស្ដាប់សំដីនាងមោហនីកូនស្រីចប់សព្វគ្រប់, នាងក៏យកល្អីធំនោះមកដាក់រូបិយមាសនឹងទៅប្រុស- យកទៅដាក់ចោលនៅមុខព្រះបរមរាជវាំងតាមបង្គាប់ព្រះយោគី ។

ក្នុងពេលនោះ ព្រះមហាក្សត្រទ្រង់និមិត្តឃើញបិសាចមួយមានដៃដប់, ក្បាលប្រាំ, ភ្នែកបី; ហើយនៅលើក្បាលនីមួយៗមានព្រះចន្ទមានព្រះទន្តធំៗ កាន់នៅនឹងដៃដែកមានធ្មេញបី ។ បិសាចនោះមានរូបទ្រង់ទ្រាយសំបើមអស្ចារ្យ មកដល់ចំព្រះភ័ក្ត្រព្រះមហាក្សត្រក៏ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស! នៅក្លោងទ្វារខាងមុខមានល្អីមួយធំ ។ សូមទ្រង់យកទារកដែលនៅក្នុងល្អីនោះ, ទារកនោះជាអ្នកគ្រប់គ្រងព្រះរាជអាណាចក្រព្រះអង្គក្នុងកាលជាអនាគត" ។ ព្រះមហាក្សត្រិយ៍ទ្រង់ក៏បើកព្រះនេត្រ មានព្រះរាជឧង្គារទៅកាន់ព្រះអគ្គមហេសីអំពីរឿងដែលទ្រង់និមិត្តនោះ ។ ទ្រង់បានតើនឡើងពីក្រឡា

ព្រះបន្ទំ ទ្រង់ទតយល់ល្អីមួយធំនៅក្បែរទ្វារខាងមុខព្រះបរមរាជវាំង ។ ទ្រង់បានបើកល្អីនោះហើយ ទតទៅយល់ទារកម្នាក់ព្រមទាំងរូបិយមាស ១.០០០ ។ ទ្រង់ក៏បានបីទារកនោះយកមកដាក់លើព្រះជង្ឃា (ជង្គង់) នៃព្រះអគ្គមហេសី ។ ឯរូបិយមាសទ្រង់ឲ្យនាយទ្វារបាលយកមកតាមក្រោយព្រះអង្គ ។ ពេលនោះទទួលបុព្វណ្ហសម័យ, ព្រះមហាក្សត្រិយ៍ទ្រង់ចេញពីក្រឡាព្រះបន្ទំ, ត្រាស់បង្គាប់ឲ្យហៅបណ្ឌិតទីងហោរាហើយមានបន្ទូលថា: "តើនៅលើរូបទារកនេះមានរាជលក្ខណៈឬទេ?" ។

គ្រាន់ពេលនោះមានព្រាហ្មណ៍ម្នាក់ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "បពិត្រមហារាជ! នៅលើរូបទារកនេះមានលក្ខណៈបីយ៉ាងគឺៈ ដើមទ្រូងធំទូលាយ, ថ្ងាសខ្ពស់, មុខធំ ។ ក្រៅពីលក្ខណៈខាងលើ ទារកនេះមានរូបលក្ខណៈសាមសិបពីរយ៉ាងទៀត ដែលផ្សេងពីមនុស្សសាមញ្ញ ។ សូមទ្រង់កុំព្រួយព្រះរាជហឫទ័យអ្វីសោះឡើយ ទារកនេះមុខជានឹងបានសោយរាជសម្បត្តិជាស្តេចក្នុងកាលជាអនាគតមិនខាន" ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះទ័យសោមនស្សពន់ពេក, ទ្រង់បានធ្វើព្រះរាជអំណោយដល់ព្រាហ្មណ៍ហោរានោះ នូវខ្សែគជខ្សែព្រមទាំងសេរីវត្ថុឯទៀតជាច្រើន ហើយទ្រង់ត្រាស់បង្គាប់ឲ្យដាក់ព្រះនាមទារកនោះ ។ តែពួកបណ្ឌិតបានក្រាបបង្គំទូលទ្រង់ថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គទ្រង់គន់គិតព្រះអគ្គមហេសី ហើយ

សូមយកព្រះកូសាវែងស្រោបព្រះអង្គទាំងពីរ ហើយសូមព្រះអគ្គមហេសីដាក់ព្រះរាជបុត្រលើព្រះជង្ឃ ។ សូមទ្រង់ត្រាស់បង្គាប់ឲ្យប្រជារាស្ត្រមកជួបជុំនៅទីនេះ ដើម្បីនឹងរៀបពិធីបុណ្យជាតុទ្បារិក ។ នៅក្នុងពេលនោះ ទូលបង្គំនឹងដាក់ព្រះនាមព្រះរាជបុត្រទៅតាមបទបញ្ញត្តិគម្ពីរពិសិដ្ឋ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់បង្គាប់ទៅរដ្ឋមន្ត្រីរបស់ព្រះអង្គឲ្យរៀបចំតាមបង្គាប់ហោរា ។ រដ្ឋមន្ត្រីក៏បានចាត់មនុស្សឲ្យផ្សាយដំណឹងអំពីបដិសន្ធិព្រះរាជបុត្រ ព្រមទាំងហៅប្រជារាស្ត្រទៅកាន់ពិធីបុណ្យនោះ ។

ប្រជារាស្ត្រទាំងប្រុសស្រីក៏បាននាំគ្នាទៅកាន់ព្រះបរមរាជវាំង គ្រប់គេហដ្ឋានបានធ្វើបុតប្លាយបង្ហាយពរជ័យមង្គលសិរីសួស្តីគ្រប់ចំពូក, ក្រុងមហោស្រពព្យួរសព្វក្នុងព្រះបរមរាជវាំងហើយក៏ចាប់ផ្តើមបុណ្យនោះ ។

ព្រះមហាក្សត្រិយ៍និងព្រះអគ្គមហេសី ទ្រង់បានដាក់ព្រះរាជបុត្រលើព្រះជង្ឃ ទ្រង់គង់នៅក្នុងព្រះតំណាក់ដែលគេរៀបចំទូវគ្រឿងសក្ការបូជា ព្រមទាំងខាទនិយាហារមាននំបន្អែមជាដើម ក្នុងពេលវិវាហមង្គលការឬពិធីបុណ្យផ្សេងៗ ហើយដល់ពិធីបុណ្យរួច គេយកនំបន្អែមនោះចែកទៅជាទាន ។ ពួកព្រាហ្មណ៍ក៏តាំងសូត្រធម៌វេទ ។ មានព្រាហ្មណ៍ម្នាក់ជាបណ្ឌិតហោរា បានពិនិត្យមើលពួកតារាទាំងប៉ុន្មានកំណត់ពេលវេលាដ៏គួរនឹងដោតជតាកំណើត ហើយក៏ដាក់ព្រះនាមព្រះរាជបុត្រថាហរិទត្ត (Haridatt ថ្វែថាអំណោយព្រះវិស្ណុ) ។

ហរិទត្តទ្រង់ចម្រើនវ័យវឡូនាការរាល់ថ្ងៃ ។ លុះដល់អាយុ ៩ ឆ្នាំទ្រង់បានអានជាច់នូវសាស្ត្រ ៦ យ៉ាងនឹងវិទ្យាសាស្ត្រ ១៤ យ៉ាងហើយ មានប្រាជ្ញាក់ងវៃជាបំផុត ។ ក្នុងពេលនោះ ធនុៈព្រះអាទិទេពក៏បាន សម្រេច ។ ព្រះវរបិតា ព្រះវរមាតាទ្រង់សោយព្រះទិវង្គត ។ ព្រះរាជបុត្រនោះទ្រង់បានឡើងសោយរាជសម្បត្តិ ទ្រង់បានគ្រប់គ្រងប្រជារាស្ត្រដោយយុត្តិធម៌ ។ ដល់ទ្រង់គ្រប់គ្រងរាជសម្បត្តិ បានពីរបីវស្សា ទ្រង់ព្រះតម្រិះថាៈ "អញកើតមកក្នុងលោកនេះ ដោយសារបិតាមាតា របស់អញ ។ តើអញបានប្រព្រឹត្តករណីយកិច្ចអ្វីចំពោះលោកអ្នកដ៏មាន គុណទាំងពីរ, មានសុភាសិតមួយពោលថាៈ អ្នកណាដែលមានចិត្ត សប្បុរសចំពោះអញនឹងអ្នកដទៃ អ្នកនោះជាបណ្ឌិត, ដល់ធ្វើមរណកាលទៅនឹងទៅកើតឯស្ថានសួគ៌ ។ តែអ្នកណាមួយមានចិត្តមិនបរិសុទ្ធ ស្អាត, ធ្វើធុតង្គសីងស្ថាធ៌, ឲ្យទានសូត្រធម៌សិក្សារៀនសៀវភៅពិសិដ្ឋ មិនបានការ ។ ករណីយកិច្ចចំពោះវិញ្ញាណក្ខន្ធដែលស្លាប់បាត់បង់ទៅ ហើយ ធ្វើដោយគ្មានសទ្ធាមិនបានផល ហើយដីដូនដីតាយើងក៏មិន អាចសោយនូវផលនោះបាន" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រិះដូច្នោះហើយ ទើបមានព្រះបន្ទូល នឹងព្រះអគ្គឯងថាៈ "ករណីយកិច្ចរបស់អញ គឺការរៀបចំពិធីបុណ្យព្រះ ធាតុនៃព្រះវរបិតាព្រះវរមាតា ហើយនឹងធ្វើសក្ការបូជាចំពោះវិញ្ញាណក្ខន្ធ របស់លោកអ្នកដ៏មានគុណទាំងនេះ" ។

ទ្រង់ស្តេចយាងទៅកាន់គយា, ទ្រង់ក៏បួងសួងដល់ព្រះបរមនាមព្រះវរបិតាព្រះវរមាតា ហើយទ្រង់បានរៀបចំសក្ការបូជា មានបិណ្ឌៈ (ពំនូតបាយឬម្សៅដែលគេយកទៅបូជាសព) នៅលើស្ទឹងផល្គុ, ទ្រង់បានទតទៅឃើញដៃបីលើកចេញពីលើទឹក ។ ទ្រង់មានព្រះវិចិកិច្ឆា (ព្រះទ័យឆ្ងល់សង្ស័យ) ពន់ពេក ហើយទ្រង់មិនយល់ថា: បិណ្ឌៈនេះមិនដឹងជាបូជាទៅអ្នកណា ។

ដល់ពណ៌នាចប់ហើយ អារក្សក៏ក្រាបទូលមហាកដថា: "បពិត្រមហាកដពិក្រម! តើបិណ្ឌៈនេះ ត្រូវបូជាទៅអ្នកណា?" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "ត្រូវឲ្យទៅចោរ" ។

អារក្សក្រាបទូលតបព្រះមហាក្សត្រិយ៍ថា: "ព្រោះហេតុអ្វី?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលតបទៅវិញថា: "កិច្ចដែលព្រាហ្មណ៍បង្កើតទារកនោះ គេទិញរូបហើយ, មហាកដសុទក្សបានទទួលរូបិយមាសមួយពាន់ដើម្បីនឹងបីបាច់ថែរក្សាទារកនោះ ។ ព្រាហ្មណ៍នឹងមហាកដសុទក្សមិនត្រូវបានបិណ្ឌៈនោះឡើយ" ។

អារក្សបានស្តាប់នូវព្រះបន្ទូលព្រះបាទពិក្រម ក៏វិលត្រឡប់មកកាន់រុក្ខជាតិវិញ ។ ព្រះមហាក្សត្រិយ៍ចងអារក្សនោះរួចទ្រង់លីលើព្រះអង្សាយកទៅ ។

ចប់ រឿងទី ១៨ នៅមានរឿងទី ១៩ តទៅទៀត

---

# រឿងស្លាប់ព្រោះជាតិ

មាន ៣ ឈុត

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(ត-ចប់)

---

### វណ្ណនារី

*បងមិនខ្លាចបាបទេ បងរាយលោកយាយ?*

### ភគី

*ទេអូន! ត្រង់បុណ្យបាបលើកចោល ១ ពេលសិន! កុំឲ្យភ្ជាប់ គ្រាន់តែម៉ាក់ឯងស្លាប់ភ្លាម គាត់រកប្រពន្ធឲ្យប៉ាភ្លាម! ត្រង់ឯងទៅកំឡោះ ឯណោះម្ដេចក៏គាត់មិនគិតផង ទៅគិតឯប៉ាដែលមានមួងរូបទៅហើយ ៗ កុំមាត់អូន! ឮសូរតែមាត់ស្រែកចូលមកហើយ កុំមាត់នៅឲ្យស្ងៀម ៗ*

ឆាកទី ៤

## *ភគា-ភគី-វណ្ណនារី-តាភ*

### ភគា

*(ស្រែកនៅក្នុងឆាករួចចេញមកក្រៅ) អៃយ៉ូយ, កូនអើយ! គេបាញ់ប៉ាហើយ! ចោរលួចបាញ់ប៉ាហើយ! កូន! អៃយ៉ូយ! ៗ*

### ភគី

*អ្វីប៉ា?*

ភាគា

គេលួចបាញ់ប៉ាហើយកូន !

វណ្ណ៍ធារី

ត្រូវត្រង់ណាលោកប៉ា? ត្រូវត្រង់ណា?

ភាគា

ចំដើមទ្រូងតែម្ដង កូនអើយ ! អូយ !... ។

វណ្ណ៍ធារី

យាយអើយ ! គេលួចបាញ់ប៉ាខ្ញុំហើយ ។

ភាគី

អូននៅមើលប៉ាចុះ ទុកឲ្យបងដេញតាមអាចោរកំណាច ។

វណ្ណ៍ធារី

ឱ! លោកប៉ាអើយ ! កម្មអ្វីក៏ក្រាស់ម៉្លេះ ។

តារា

អ្ហូកូន ! កូនមាសម្ដាយ, ឱកូនអើយ ! ម្ដាយកើតទុក្ខយ៉ាងធំទៀតហើយ ! ចុះអាណាហ្នឹងក៏ចិត្តអ្វីធំសម្បើមម៉្លេះ ម្ដេចក៏មិនទាញកាំភ្លើងបាញ់វាទៅវិញទៅ ។

រាគា

ខ្ញុំនឹកឃើញដែរអ្នកម្តាយ, សេចក្តីសង់សឹក ៗ ប៉ុន្តែដោយខ្ញុំនឹកឃើញថាបើនឹងបាញ់តៈទៅក់ ក៏ជាការឥតប្រយោជន៍ គឺគ្នាចង់បានថ្មីដៃហើយ បានជាគ្នាខំមកប្ដូរជីវិតយ៉ាងដូច្នេះ ៗ

តារា

ចុះកូនស្គាល់មុខវាទេ អាចោរកំណាចនោះ!

រាគា

នៅមិនឆ្ងាយអំពីនេះប៉ុន្មានទេ បច្ចាមិត្តរបស់ខ្ញុំ កាលដែលខ្ញុំទៅប្រតិបត្តិការ ខ្ញុំបានប្រកែកប្រណាំងឈ្លោះគ្នានឹងស័ក្តិពីរម្នាក់ដែលជាអ្នកមានឋានន្តរស័ក្តិស្មើនឹងខ្ញុំ ៗ រូបគេនឹងខ្ញុំក៏ទាញគ្រឿងសស្ត្រាវុធប្រុងតែនឹងធ្វើកិច្ចអាឃាតតែដោយខ្លួន ៗ ប៉ុន្តែបានលោកវរសេនីយ៍ឯកលោកឃាត់មិនឲ្យខ្ញុំប្រព្រឹត្តអំពើអាក្រក់ដ៏លាមកនេះ ៗ សេចក្តីគុំគួនរបស់សត្រូវខ្ញុំក៏ចេះតែមានជាប់រហូតមក ឯអ្នកមកប៉ងនឹងសម្លាប់ខ្ញុំនេះគឺជាកូនរបស់វណ្ណ-ហួននេះឯង ៗ

តារា

យីអាវណ្ណ-ហួន! អាវណ្ណ-ហួនមិនគួរចិត្តដល់ម្ល៉ឹងទេ! អាប្រើកូនរបស់អា ឲ្យមកបាញ់សម្លាប់កូនអញយ៉ាងដូច្នេះ អាឯងគង់មានថ្ងៃណា

មួយ អញធ្វើឃាតកម្មតបអាវិញជាពុំខាន អាក្បត់ផែនដី! អាក្បត់ជាតិ! អាឯងគ្មានរួចពីកណ្ដាប់ដៃរបស់អញទេ ៗ

## ភគា

អ្នកម្ដាយសូមអត់ទោសទៅចុះ! សូមអ្នកម្ដាយកុំធ្វើឃាតតបនឹងសត្រូវដែលមកបំផ្លាញជីវិតរបស់ខ្ញុំនេះ ៗ អ្នកកុំធ្វើឲ្យសោះ ជីវិតខ្ញុំមួយបើនឹងស្លាប់ទៅក៏មានប្រយោជន៍ដល់ប្រទេសជាតិ ក្នុងពេលពីមុនជាច្រើនណាស់ហើយ បើសិនណាខ្ញុំស្លាប់ នាមរបស់ខ្ញុំក៏មិនសាបសូន្យដែរ ស្លាប់ដោយសារប្រទេសជាតិប្រសើរណាស់អ្នកម្ដាយ កេរ្ដិ៍ឈ្មោះមិនមែនអន្តរាយបាត់សាបសូន្យដូចជាអ្នកដទៃទេ ៗ ហេតុនេះអ្នកម្ដាយ បើកាលណាខ្ញុំដាច់ខ្យល់ស្លាប់ទៅវេលាណា សូមអ្នកម្ដាយកុំរករឿងហេតុនេះឲ្យសោះ សូមបំភ្លេចចោលតែម្ដងទៅ កុំប្ដឹងផ្ដល់ធ្វើអ្វី គឺជាព្រេងសំណាងរបស់ខ្ញុំ មានកុសលផលល្អណាស់ដែលបានទទួលអកាលមរណៈយ៉ាងដូច្នេះ ៗ

## ភាគទី ៥

## វន្ទី-ភគា-ភគី-វណ្ណនារី-តារា

### វន្ទី

អើ! អាឯងបានការធ្វើហើយជាន់ហ្នឹង ធ្វើភាឲ្យដឹងចិត្តថាអ្នកវន្ទីម្ដង! កុំឲ្យភាឆ្ងាច់ អាកូនរង្វេស ៗ ឯណា ទៅណាហើយ អារមិលគុណនោះ!

ឯងមិនរួចពីកណ្ដាប់ដៃអញទេ ៗ (ស្ទាំងកាំងដោយឃើញកូនដេកស្ដូក)

នែ! វាស៊ីហ្នឹង! បានជាដេកស្ដឹងស្ដូកយ៉ាងនេះ អាពកា! ៗ

រាគា

អ្នកម្ដាយ! ចូរអ្នកម្ដាយកុំភ័យធ្វើអ៊ុំអ៊ីពីកិច្ចអាពាហ៍ពិពាហ៍របស់ខ្ញុំ, អ្នកម្ដាយមិនបានអាម៉ាស់មុខដោយសារខ្ញុំទេ ៗ ចូរអ្នកម្ដាយយករឿងរ៉ាវដែលអ្នកម្ដាយបានឃើញជាក់នឹងភ្នែកនេះ ទៅជំរាបជូនអ្នកម្ដាយថ្លីទៅចុះ! ច្បាស់ជាគេមិនរករឿងហេតុនឹងអ្នកម្ដាយទេ ហើយអ្នកម្ដាយក៏មានសេចក្ដីត្រេកអរក្នុងចិត្តដែរ! ពោលគឺអ្នកម្ដាយមិនបានអាម៉ាស់មុខដោយសារខ្ញុំទេ ៗ.

វីស្ន

(សួរទៅអ្នកតាក់) អ្នក! វាយ៉ាងដូចម្ដេចហ្នឹង?

តារា

ចា៎សអ្នក! មិនគួរសោះ គ្រាន់តែកូនចេញទៅក្រៅ អើតកស្ដោះទឹកមាត់នៅពនហាល ១ ភ្លែត ស្រាប់តែមានអាចោរកំណាចមិនដឹងជាមកពីណា មកលបបាញ់កូនត្រូវចំដើមទ្រូងតែម្ដង ៗ

វីស្ន

(ភ័យ) កូនមាសម្ដាយៗ! កូនមុខតែស្លាប់ចោលម្ដាយហើយ, កូនអើយកូន! យីចំជាពិបាកក្នុងចិត្តខ្ញុំណាស់លោកអើយ! មនុស្សយើង

ពាមានអាចិត្តអាក្រក់! អាចិត្តល្អ! អាចិត្តអន្តរាយ! អាឈាមខ្មៅ អាហ្នឹងពាដេករកតែរឿងហេតុនឹងគេតែម្តង! យីចំហើយហ្ន៎! ហើយចុះកូនឯងស្គាល់មុខពាទេ? ។

រាគា

បើទុកជាខ្ញុំស្គាល់មុខពា ក៏អ្នកម្តាយមិនត្រូវទៅរករឿងហេតុធ្វើអ្វីដែរ, អ្នកម្តាយអកាលមរណៈរបស់ខ្ញុំយ៉ាងដូច្នេះប្រសើរណាស់។ ចូរអ្នកម្តាយចាំឲ្យច្បាស់ថានាមរបស់ខ្ញុំមិនសាបសូន្យទេ សេចក្តីមរណភាពដោយសារជាតិប្រសើរក្រៃ ។

វិទ្ធី

មិនគួរសោះ! បើថាមនុស្សចិត្តអាក្រក់ទៅចុះគួរតែស្អប់! ចុះកូនរបស់ខ្ញុំជាមនុស្សមួយ អ្នកមានគុណដល់ផែនដីដែរ, បានធ្វើការកងកងទ័ពនៃក្រុមរក្សាប្រទេសជាតិតាំងតែពីអាយុ ១៨ ឆ្នាំ រៀងរហូតមកទាល់នឹងចាស់ប៉ុណ្ណោះហើយ (ចំនួនអាយុ ៤០ ឆ្នាំគត់) បានធ្វើការតស៊ូទាល់តែមានថ្វីដៃ, រាជការទាំងផែនដីក៏បានស្គាល់កិរិយានិងសមត្ថភាពដ៏ឧត្តមរបស់កូនខ្ញុំ, បានពាក់ស័ក្តិរៀងរហូតតាំងពីតូចទាល់តែឡើងធំៗជាលំដាប់, បានឋានន្តរៈជាអនុសេនីយ៍ទោ ។ កូនខ្ញុំ បានយកកម្លាំងនឹងបញ្ញាទៅការពារកងអាណាខេត្ត បានសន្តិសុខធ្វើការឲ្យផលដល់នគរប៉ុណ្ណឹងហើយ នៅតែមានមនុស្សអាក្រក់ពាមិនពេញចិត្តពាទៀត, ពាប្រែណែនទិន្នានឹងកូនខ្ញុំ នេះហៅជាចំហើយហ្ន៎! ។

ខំការនាធមិទៅកូន ! ម្ដាយគ្មានអ្វីជាទីពឹងទេ, គ្មានអ្នកនឹងចែកឲ្យអ្នកបានទេ គង់ពេលនេះ, មានតែព្រះពុទ្ធព្រះធមិព្រះសង្ឃនេះហើយជាទីពឹង ។ ខំការនាទៅកូន ! ពុទ្ធោ អរហំ ។ ។

រាគា

បាទអ្នកម្ដាយ ! កូនខ្ញុំទៅណាហើយ ? ចូរចូលមកជិតប៉ាកូន ! ។

រាគី

(រត់ចូល) រត់រកមិនឃើញទេលោកប៉ា ! មិនដឹងជារត់គេចទៅតាមផ្លូវណាទេ ! តាមផ្លូវមាត់ទន្លេក៏មិនដឹង តាមផ្លូវទៅពាមរក៏មិនដឹង ខ្ញុំរត់ស្ទាត់រកទាំងអស់ រកមិនឃើញ ។

រាគា

ចុះអញមានប្រើឯងឯណា ឯងចេះតែរត់រកតាមអំពើចិត្តឯងទេតើ ។ កូនឯងយកកូនសោនេះទៅចាក់ទូយកសៀវភៅទាំងពីរ ដែលអញដាក់នៅលើដើងពានមក ។

រាគី

សៀវភៅហ្នឹងឬលោកប៉ា ?

រាគា

វណ្ណនារី កូន ! កុំយំធ្វើអ្វី ធ្វើម្ដេចកម្មរបស់ឯង ឪពុកនឹកស្មានថានឹងបានទំនុកបំរុងអ្នកឲ្យរៀនសូត្របានដោយបរិបូណ៌ ប៉ុន្តែធ្វើម្ដេចឥឡូវ

ប្រាជ្ញផ្លូវអក្សរសាស្ត្រ, គឺតាមផ្លូវអក្សរសាស្ត្រនេះហើយកូន! ដែលអាចលើកតម្កើងកម្ពុជរដ្ឋឲ្យចំរើនទៅថ្ងៃក្រោយ ៗ កូន! បើកាលណាប្រឡងជាប់សញ្ញាប័ត្រហើយ ចូរកូនទៅរៀនតបំណេះខាងមុខទៀតនៅសាលាគរុវិជ្ជាកំពេញ ដើម្បីនឹងបញ្ជាក់អំពីចំណេះរបស់កូន ត្រូវកូនរៀនឲ្យជាប់ថ្នាក់ បានឋានៈដ៏ខ្ពង់ខ្ពស់ក្នុងក្រសួងសិក្សាធិការ, ប្រឡងឲ្យបានឋានៈជាសាស្ត្រាចារ្យចាំឈប់កូន! ៗ

កូនមាសឪពុកទាំងពីរ! ចូរកូនកុំភ្លេចបណ្ដាំឪពុកឲ្យសោះ ត្រូវកូនចារទុកក្នុងវិញ្ញាណរបស់កូនឲ្យជាប់. សំដីរបស់ឪពុកផងប៉ុន្មានមាត់នេះ ៗ

ឪពុកមុខជានឹងទទួលសេចក្ដីអញ្ជើញនៃមច្ចុរាជហើយ ៗ បុកណែនក្នុងដើមទ្រូងណាស់កូន! ៗ

## វិណ្ណារី

បាសលោកប៉ា! កូននឹងទទួលចាំឲ្យជាប់នៅក្នុងចិត្តកូនមិនឲ្យភ្លេចទេសេចក្ដីប្រៀនប្រដៅរបស់លោកប៉ា ៗ

## រាគា

អ្នកម្ដាយ! អ្នកមានគុណទាំងពីរ ចូរអ្នកម្ដាយអាណិតខ្ញុំជួយចិញ្ចឹមកូនខ្ញុំទាំងពីរនេះផង ទំនុកបំរុងឲ្យរៀនសូត្រឲ្យបានពេញបរិបូណ៌ ប្រាក់

អាយុឪពុកដល់ហើយ ។ កូន! កូនប្រុស! កូនស្រីមាសឪពុក' ឪពុកគ្មានអ្វីជារបស់មានដម្លៃនឹងចែកឲ្យកូនទេ មានតែសៀវភៅវាំងពីរនេះហើយ ។ ភាគីកូន! ឪពុកទុកតែស្ដីសៀវភៅនេះឲ្យឯង សៀវភៅវាងសឹកសង្គ្រាមជ័យ ចូរកូនយកទៅរៀនចុះ ។ អំណោះឥតពីឪពុកទៅពេលណា ដល់ពេលប្រឡងឌីប្លូមហើយ ត្រូវកូនប្រឡងចូលសាលាយុទ្ធនាធិការខេមរភូមិន្ទ ១ រំពេច ដើម្បីនឹងរៀនចំណេះវិជ្ជាខាងពលិកម្ម ដើម្បីនឹងធ្វើការបំរើប្រទេសជាតិដោយផ្លូវសឹកសង្គ្រាម ។ កុំខ្លាចស្លាប់កូន! បើអ្នកបានស្លាប់ ដូចឪពុកយ៉ាងដូច្នេះប្រសើរណាស់ ។ បើសិនណាជាកូនបានទទួលសេចក្ដីមរណភាព នៅលើទីសមរភូមិនោះ ព្រេងសំណាងរបស់កូនក៏រឹតតែវិសេសណាស់ សង្ឃឹមដល់ទគរកុំខ្លាចស្លាប់ ស្លាប់ក្រោមទង់ជាតិគម្ពុជាប្រសើរណាស់ ។

ភាគី

បាទលោកប៉ា! ខ្ញុំបាទសូមធានាសច្ចាថានឹងទទួលប្រតិបត្តិតាមគន្លងធម៌ដ៏ល្អប្រពៃនេះ សូមលោកប៉ាជឿជាក់ថា ប្រសាសន៍លោកប៉ាទាំងប៉ុន្មាននេះខ្ញុំទទួលថែរក្សាទុកមិនឲ្យក្លេច ។

ភាគា

វណ្ណ-នារីកូនស្រីប៉ា! ចូរកូនទទួលយកសៀវភៅនេះ គឺជាសៀវភៅច្បាប់សម្រាប់ធ្វើជាអ្នកគ្រូ, កូនត្រូវបំរើប្រទេសជាតិដោយកំលាំងចិត្តនឹង

៥០ ម៉ឺនរៀលនេះ ដែលកូនបានសន្សំទុក ចូរអ្នកម្ដាយទុកលៃលកគ្រាន់តែចំណាយឲ្យកូនខ្ញុំទាំងពីរនេះ រៀនសូត្រឲ្យបានជាសិរី បើចាយប្រាក់នេះអស់ហើយ កេរមត៌ករបស់ខ្ញុំទាំងប៉ុន្មាន ត្រូវអ្នកម្ដាយជំនុំគ្នាលក់ទៅចុះ! ដើម្បីនឹងយកប្រាក់មកចិញ្ចឹមកូនសំឡាញ់របស់ខ្ញុំទាំងពីរនេះ ដើម្បីនឹងធ្វើការបំរើប្រទេសជាតិទៅអនាគត ។

ខ្ញុំសូមខមាទោសចំពោះអ្នកម្ដាយទាំងពីរ លើកិច្ចការណ៍ណាដែលខ្ញុំបានប្រព្រឹត្តផ្ទុយនឹងអ្នកម្ដាយ សូមកុំឲ្យខ្ញុំមានវេរពាបពៀរ ។

(វាំងននធ្លាក់)

(ខ្មោចនេះ ត្រូវគេបដោយទង់ជាតិខ្មែរ)

ចប់

គ្រប់គ្រងល្អ នាំឲ្យចំរើន

គ្រប់គ្រងអាក្រក់ នាំឲ្យវិនាស

ការគ្រប់គ្រងប្រជាជនទាំងឡាយដោយល្អ ជាមធ្យោបាយដ៏ប្រសើរដែលនាំទៅកាន់ឃ្លាំងគឺស្ថានសួគ៌, ការសង្កត់សង្កិនប្រជាជនខ្លាំង ជាផ្លូវនាំឲ្យវិនាស សេចក្ដីចំរើន ឲ្យកើតសេចក្ដីអាក្រក់នឹងការអត់ឃ្លាន ។

បញ្ញត្តន្រ្ត:

# រឿងចិញ្ចៀនទិព្យ

## អ្នកស្រីសារិយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

---

មាននិទានថា កាលពីព្រេងនាយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គគ្រងទ្វីបទាំងមូល ទ្រង់ប្រកបដោយគុណធម៌ដ៏ប្រពៃ ទ្រង់ជំនុំជំរះក្តីដោយសុចរិត ហើយទ្រង់បង្ហាញសមភាពចំពោះមហាជនទាំងមូល ។ គង់សម័យរាត្រីមួយ ពេលដែលទ្រង់កំពុងផ្ទំលក់ ទ្រង់សុបិននិមិត្តថា "មានទេវតាមកថ្លែងប្រាប់ទ្រង់ថា: ឱ! ព្រះមហាក្សត្រអើយ! សូមទ្រង់តើនឡើងគង់សេះបានេះ ទ្រង់ស្តេចត្រោះទៅកន្លែងមួយដែលនៅក្នុងព្រៃភ្នំ ហើយនៅទីណាដែលជើងសេះផុងចុះទៅក្នុងដី សូមទ្រង់ជីកដីត្រង់កន្លែងនោះ ទ្រង់នឹងប្រទះឃើញគំរបមួយ លុះទ្រង់បើកគំរបនោះទៅ ទ្រង់នឹងឃើញជណ្តើរមួយវែងចុះទៅក្រោម ដែលមានដល់ទៅ ៣០០ កាំ សូមទ្រង់យាងចុះតាមជណ្តើរនេះដោយតមកុំពោលពាក្យអ្វីឲ្យសោះទាល់តែដល់ទៅក្រោម នៅចុងបំផុតទ្រង់នឹងឃើញទ្វារមួយទៀតដែលមានកូនសោជាប់នៅនោះ ទ្រង់យកកូនសោបើកទ្វារនោះទៅដោយស្ងៀមស្ងាត់ ទ្រង់នឹងឃើញកំណប់មួយដ៏ស្តុកស្តម្ភ មានរូបលង្ហិនមួយនៅរក្សា រូបនោះនឹងស្រែកគំរាមទ្រង់, ប៉ុន្តែសូមទ្រង់កុំខ្លាចកុំតក់ស្លុតឲ្យសោះ លុះទ្រង់ចូលទៅជិត ទ្រង់នឹងឃើញចិញ្ចៀនមួយនូវដៃរូបលង្ហិននោះ ទ្រង់យកចិញ្ចៀននោះមក, លុះទ្រង់យកចិញ្ចៀនបានវេលាណា

រូបលង់ហិននឹងអស់អំណាចលើទ្រង់នៅវេលានោះ; ចំពៀននេះប្រកបដោយលក្ខណៈ ៣ យ៉ាងគឺកាលណាទ្រង់បៀមក្នុងព្រះឱស្ឋ ទ្រង់នឹងអាចបំបាំងព្រះអង្គបាត់, កាលណាទ្រង់ដាក់ចំពៀននោះទៅលើដី បំរើរបស់ចំពៀននឹងបង្ហាញខ្លួនឲ្យទ្រង់ឃើញ ហើយវានឹងធ្វើតាមបង្គាប់ទ្រង់គ្រប់យ៉ាង, បើទ្រង់ពាក់ចំពៀននោះជាប់នៅព្រះហស្ថ គ្មាននរណានឹងមកបៀតបៀនទ្រង់បានឡើយ" ។

ព្រះរាជាទ្រង់តើនឡើងហើយភាវនាធម៌ថា "ខ្ញុំសូមឲ្យព្រះជាម្ចាស់ជួយថែរក្សាខ្ញុំកុំឲ្យអារក្សសាតាំងមកបៀតបៀនបាន" ។ ប៉ុន្តែដឹងជាអារក្សសាតាំង ឬព្រះដ៏មានព្រះហឫទ័យសប្បុរស ដែលធ្វើឲ្យនិមិត្តឃើញដូច្នេះ? ទ្រង់តើនឡើងស្រប់ព្រះភ័ក្ត្រ ទ្រង់សូត្រធម៌ថ្វាយបង្គំហើយនឹកគុណព្រះមានបុណ្យសូមលោកជួយកុំឲ្យអារក្សសាតាំងមកបៀតបៀនទ្រង់បាន រួចទ្រង់ក៏ផ្ទុំទៅវិញ ។

នៅក្នុងពេលដែលទ្រង់កំពុងផ្ទុំលក់ ទេវតាមកពន្យល់សប្តិទៀតថា: "តើនឡើងសូមទ្រង់គង់សេះបានេះទៅកន្លែងនុ៎ះ លុះសេះផុងជើងនៅកន្លែងណា សូមទ្រង់ជីកដីកន្លែងនោះ ទ្រង់នឹងឃើញគំរបមួយ សូមទ្រង់បើកគំរបនោះឡើងហើយធ្វើយ៉ាងនេះៗ ដូចដែលបានបង្គាប់ពីកាលដំបូង" ។ ព្រះរាជាទ្រង់តើនឡើងដោយវិតក្កទ្រង់ស្រប់ព្រះភ័ក្ត្រ សូត្រធម៌ហើយថ្វាយបង្គំពីរដង ទ្រង់សរសើរដល់គុណរបស់ព្រះជាម្ចាស់ហើយក៏ផ្ទុំទៅវិញ ។

ព្រះរាជាទ្រង់សុបិននិមិត្តជាគំរប់បីដង ដូចកាលពីរដងដំបូងទៀត ទ្រង់តើនឡើងហើយទ្រង់រំពឹងគិតថា: " ការយល់សុបិននិមិត្តនេះ ប្រាកដជាបណ្តាលមកអំពីព្រះដ៏មានព្រះហឫទ័យសប្បុរស ពុំមែនមកពីអារក្សសាតាំងទេ " ៗ ទ្រង់ក្រោកឡើងពីក្រឡាបន្ទំស្រប់ព្រះភ័ក្ត្រហើយ ទ្រង់ភាវនាធម៌លុះដល់ភ្លឺ ៗ កាលនោះទ្រង់បង្គាប់ឲ្យរៀបក្បួនសេនាទាហាន ហើយត្រាស់បង្គាប់ឲ្យគេរកសេះបាដែលទេពនិមិត្តបង្គាប់ឲ្យយក ៗ គេក៏នាំសេះនោះមកថ្វាយទ្រង់ ៗ

ព្រះរាជាទ្រង់ឡើងគង់សេះឆ្ពោះទៅកន្លែងដែលទេពនិមិត្តបង្ហាញជាមួយនឹងព្រះរាជបុត្រាបីព្រះអង្គដែលព្រះជាម្ចាស់ថ្វាយជារង្វាន់ដល់ទ្រង់ ៗ លុះមកដល់ទីភ្នំ ព្រះរាជាទ្រង់បំផាយសេះសំដៅទៅកន្លែងនោះបន្តិច ស្រាប់តែជើងសេះផុងទៅក្នុងដី ទ្រង់លោតពីលើសេះចុះមក ៗ លុះសេនាទាហានមកជួបជុំកាលណា ទ្រង់ក៏ត្រាស់បង្គាប់ឲ្យដកជើងសេះ ហើយជីកដីនៅកន្លែងនោះភ្លាម ៗ សេនាទាំងឡាយក៏ធ្វើតាមព្រះរាជបញ្ជា លុះជីកជ្រៅបន្តិចទៅក៏ប្រទះឃើញគំរបមួយ សេនាក៏ទូលព្រះមហាក្សត្រថា: " ព្រះករុណាជាម្ចាស់ យើងបានឃើញគំរបមួយនៅទីនោះ " ៗ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយក៏បង្គាប់ឲ្យដំឡើងព្រះពន្លានៅទីនោះ ទើបទ្រង់បង្គាប់ឲ្យបើកគំរបឡើង ៗ នៅក្រោមគំរបនោះមានកាំជណ្តើរ ១ វែង ៗ ព្រះរាជាចង់យាងចុះទៅហើយ ប៉ុន្តែពួកសេនា

ទាហាននឹងមន្ត្រីតូចធំ ចូលទៅក្រាបអង្វរទ្រង់ថា: "សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង កុំទ្រង់ចុះធ្វើអ្វី ទូលព្រះបង្គំជាខ្ញុំពល់គ្នានឹងចុះទៅជំនួស" ។ ប៉ុន្តែព្រះមហាក្សត្រមានព្រះបន្ទូលថា: "គ្មាននរណាដទៃទៀតត្រូវចុះ ក្រៅអំពីអញទេ" ។ ក្រោយនោះ ព្រះរាជបុត្រាច្បងនឹងបន្ទាប់ពីរព្រះអង្គស្ទុះចូលទៅអង្វរទ្រង់ទៀតថា: "ព្រះបិតា! ទូលព្រះបង្គំជាខ្ញុំទាំងពីរនាក់នឹងចុះជំនួសព្រះអង្គ" ។ ប៉ុន្តែព្រះរាជានៅតែឆ្លើយថា: "គ្មាននរណាដទៃត្រូវចុះទេ ក្រៅពីអញ" ។ នៅខណៈនោះ ព្រះរាជបុត្រាពៅបង្អស់ព្រះនាម អាលី-គ្មេលេប៉ុ រត់មកជិតព្រះអង្គហើយទូលទ្រង់ថា: "ព្រះបិតា! ទុកឲ្យទូលព្រះបង្គំចុះជំនួសព្រះអង្គ បើកាលណាទូលព្រះបង្គំស្លាប់ ទុកដូចជាទូលព្រះបង្គំនៅរស់ ទូលព្រះបង្គំនឹងនិយាយរឿងរ៉ាវទូលព្រះបិតាតាមដែលទូលព្រះបង្គំបានឃើញ" ។ ប៉ុន្តែព្រះមហាក្សត្រមានព្រះបន្ទូលថា: "កូនសំឡាញ់! ចូរឯងទៅអង្គុយនៅកន្លែងឯងវិញទៅ គ្មាននរណាត្រូវចុះទៅក្នុងនោះ ក្រៅអំពីអញឡើយ" ។

ការបះបោរបស់ព្រះអង្គធ្វើឲ្យអាលី-គ្មេលេប៉ុ កើតទុក្ខជាខ្លាំងហើយទៅអង្គុយយំនៅកន្លែងខ្លួនវិញ ។

ព្រះមហាក្សត្រទ្រង់យាងចុះតាមជណ្តើរនោះ លុះតែផុត ៣០០ កាំព្រះអង្គទ្រង់ឃើញទ្វារមួយធំអស្ចារ្យ ហើយមានគូនសោមួយយ៉ាងធំជាប់

នៅនោះ ទ្រង់ចាប់យកកូនសោនោះមក ហើយនឹកព្រះនាមព្រះជាម្ចាស់យ៉ាងខ្លាំង ៗ ព្រមទាំងសូមឲ្យលោកជួយរក្សាទ្រង់ផង ទើបទ្រង់បើកទ្វារចូលទៅ ទ្រង់ឃើញរូបលង់ហិនមួយយ៉ាងធំសំបើម, នៅពេលដែលទ្រង់យាងដំរង់ចូលទៅជិត រូបនោះបញ្ចេញសម្រែកមួយយ៉ាងគ្រលាន់អស់ទាំងក្នុងផងគំរាមស្ដេចវិញ ប៉ុន្តែទ្រង់ចេះតែចូលទៅជិតហើយហូតយកចំពៀនពីស្រៀមដៃមក ។ លុះចំពៀនបានមកព្រះមហាក្សត្រគាលណា រូបនោះក៏អស់អំណាចទៅ ហើយដួលស្លាប់នៅដី ។ ព្រះកជាទ្រង់ទស្សនាអស់សម្បត្តិនៅក្នុងទីនោះ ឃើញមានត្បូងមុក្ដា, ប្រាក់និងមាសច្រើនជាពន្លឹក ទ្រង់នឹកចង់ដឹងនូវលក្ខណៈចំពៀននោះ ហើយក៏ទ្រង់ដាក់ផ្ទាល់ទៅនឹងដី ។

ក្នុងមួយរំពេចនោះ ស្រាប់តែមានអមនុស្សម្នាក់ឈរជ្រងោនៅមុខព្រះអង្គហើយពោលថា: "ទូលព្រះបង្គំជាខ្ញុំ មកជាបំរើព្រះករុណាជាម្ចាស់ជីវិតលើត្បូង, ព្រះអង្គទ្រង់តំអក់នឹងប្រើរបស់ដែលគេថ្វាយព្រះអង្គណាស់" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរថា "ឯងជាអ្វី? ឯងឈ្មោះអ្វី? ឯងធ្វើអ្វី?" ។

— ទូលព្រះបង្គំជាខ្ញុំបំរើនៃចំពៀននេះ ទូលព្រះបង្គំជាខ្ញុំឈ្មោះម៉ៃមួនដែលមានកុលសម្ពន្ធដល់ទៅ ៧០ នៅក្រោមបង្គាប់ ទូលព្រះបង្គំមានការៈនឹងទទួលធ្វើតាមព្រះរាជបញ្ជាព្រះអង្គទាំងអស់ ។ (មានត)

# រឿងប៉ូល និងវីរស៊ីនី

លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

– យី ប្រទេសនុះប្រអីចេះ? បើដូច្នេះ ត្រូវឲ្យវីរស៊ីនី ត្រឡប់មកស្រុកនេះវិញ ៗ ប្រយោជន៍អ្វីនឹងញាតិមានសម្បត្តិ ពីដើមនៅក្នុងខ្ទមនេះសប្បាយចិត្តសឹងស្លាប់ស្អាតអស់ពីចិត្ត កាលណាយកកូនកន្សែងក្រហមឬយកផ្កាមកសៀតដោតរុំជុំវិញក្បាល, ចូរត្រឡប់មកវិញ វីរស៊ីនី! ចូរចុះចោលចេញពីប្រាសាទនឹងស័ក្តិយសនោះទៅ ៗ ចូរត្រឡប់មកកាន់ទីក្នុងនេះវិញ មកលេងក្រោមម្លប់ឈើទាំងឡាយ មកលេងក្រោមដើមដូងយើងវិញ ឥឡូវប្អូនប្រហែលមានទុក្ខព្រួយខ្លាំងណាស់ហើយមើលទៅ ៗ

រួចហើយអាប៉ូលតាំងទ្រហោយំ ៗ

– “ឱលោកឪពុក! សូមលោកមេត្តាកុំលាក់នឹងខ្ញុំឲ្យសោះ សូមប្រាប់ខ្ញុំឲ្យត្រង់មកមើល តើខ្ញុំនឹងបានវីរស៊ីនី ជាប្រពន្ធឬទេ? ដោយហោចទៅ សូមឲ្យខ្ញុំដឹងតែប៉ុណ្ណេះចុះ ថានាងនៅស្រឡាញ់ខ្ញុំដូចដើមដែរឬអី? ដែលនាងបានទៅនៅកណ្ដាលពួកនាហ្មឺនធំៗ ទាំងឡាយសុទ្ធតែនៅជិតស្តេច ហើយដែលនៅលេងនឹងនាងជាធម្មតា ៗ

— នៃសំឡាញ់ ! អញហ៊ានសន្យាថានាងទៀងតែនៅស្រឡាញ់ឯង ដោយហេតុច្រើនប្រការណាស់ ហើយបើសង្កេតឲ្យដាច់ស្រេចទៅ គឺព្រោះនាងមានចិត្តធម៌ក្នុងខ្លួន ៗ

គ្រាន់តែឮសំដីប៉ុណ្ណោះ អាប៉ូលហាក់មកឱបកខ្ញុំ សប្បាយចិត្តពេកហាក់ដូចអណ្តែតខ្លួនឡើងឰដ៏អាកាស ៗ

— «លោកឪពុកជឿថាស្រីទាំងឡាយនៅឧរុប ខូចកាចដូចជាក្នុងរឿងល្ខោន នឹងរឿងក្នុងគម្ពីរដែលលោកឪពុកឲ្យខ្ញុំអានដែរឬ? ៗ

— ស្រីដែលខូចកាចមានច្រើនតែក្នុងប្រទេសណាដែលពួកប្រុសៗច្រើនសុទ្ធតែមនុស្សមុឡ្ហោ ៗ ការកំហែងនាំឲ្យកើតល្បិចបេះបញ្ឆោត ៗ

— យ៉ាងដូចម្តេចដែលគេហៅថាចិត្តមុឡ្ហោនឹងស្រី? ៗ

— កាលណាគេរៀបចំកូនឲ្យមានផ្ទះសំបែង ហើយមិនសួរចិត្តអ្នកទាំងសងខាង: ដូចស្ត្រីក្រមុំនឹងតាចាស់ ស្ត្រីអ្នកដឹងការខុសត្រូវជាមួយនឹងប្រុសទីងមោង ៗ

— ចុះហេតុអ្វីក៏គេមិនរៀបការក្មេងនឹងក្មេង ស្រឡាញ់នឹងគ្នា? ៗ

— ព្រោះនៅប្រទេសបារាំង ពួកកំឡោះមិនសូវមានធនធានល្មមនឹងរៀបការ ៗ លុះខ្លួនចាស់កាលណាទើបសន្សំទ្រព្យបានច្រើន ៗ កាលនៅកំឡោះ គេទៅខូចកាចនឹងស្រីអ្នកជិតខាង ដល់វេលាចាស់ ក៏ឈប់ស្រឡាញ់ស្រីកំណាន់នោះទៅ ៗ គេបំភាន់ស្រីក្មេងបែបយ៉ាងដូច្នេះមិន

ដីងអស់ចំនួនប៉ុន្មាន គេក៏ត្រឡប់បំភាន់ទៅវិញ មិនដឹងអស់ចាស់ប៉ុន្មានដែរ ៗ រឿងនេះគឺជាកិច្ចនៃធម៌ សម្រាប់លោកដែលគេប្រើត្រូតមនុស្សទាំងមូល អ្នកល្អថ្ងៃគួនឹងអ្នកល្អ អ្នកអាក្រក់ថ្ងៃគួនឹងអ្នកអាក្រក់ ៗ ពួកមនុស្សនៅទ្វីបប្រៀនប្រើលម្អជាទេ្វភាគដ៏សាំញ៉ាំដូច្នោះ រឿងនេះកើតមានកាន់តែច្រើនឡើង ក្នុងបណ្ដាមហាជនត្រាតែធនធានទៅគរនៅលើតែជនប៉ុន្មានរូប ទំនងនេះប្រហែលគ្នានឹងសួនច្បារ ដែលកូនឈើទាំងឡាយអាចដុះបាន លុះណាតែឈើធំៗ ជួយការពារនឹងកំដៅព្រះអាទិត្យតែមានសេចក្ដីថ្វកគ្នាបន្តិច, លំអសួនច្បារកើតមកតែពីដើមរុក្ខជាតិពីរ - បីដើម ចំណែកស្រុកទេសចំរើនរុងរឿងឡើងដោយសារមានពស្ត្រច្រើនហើយមានចិត្តស្មើគ្នា មិនមែនមកពីអ្នកមានសម្បត្តិទ្រព្យបីបួននាក់នោះឡើយ ៗ

— បើឯងចង់រៀបការ ចាំបាច់ត្រូវការឲ្យមានសម្បត្តិទ្រព្យធ្វើអ្វី? ៗ

— ដើម្បីដេកស៊ីស្រណុកក្នុងថ្ងៃណាដែលយើងមិនធ្វើការអ្វី ៗ

— ចុះហេតុអ្វីក៏មិនធ្វើការ? បើខ្ញុំធ្វើការសព្វថ្ងៃសឹងស្លាប់ ៗ

— ដ្បិតនៅទ្វីប ហត្ថកម្មថោកទាបណាស់ គេហៅថាអបញ្ញកម្ម ៗ ការក្រួរពស់នេះឯងហើយជាការគឺគេមើលងាយជាងគេបំផុត ៗ អ្នកដំនាងថ្ងៃបរជាងអ្នកស្រែ ៗ

អាប៉ូលឡូនមាត់ថា យី! អីទៅអ្នក គេមើលងាយកិច្ចការដែលចិញ្ចឹមជីវិតរបស់មនុស្ស, លោកផុតពុកមានប្រាសាទយ៉ាងហ្នឹង ខ្ញុំមិនទាន់យល់សោះ ។

គាថាស់-អកូន! ខ្លួនអ្នកដែលកើតមកហើយនៅតែក្នុងព្រៃ អ្នកមិនងាយយល់ការណ៍ប្រែប្រួលផ្លាស់ផ្តាស់នៃលោកិយឡើយ គេរៀបចំគំនិតមារយាទឲ្យត្រឹមត្រូវ មានរបៀប មិនមែនឲ្យសាំញ៉ាំទេ ។ លំអខាងក្នុង ចិត្តសប្បាយ សេចក្តីសុខស្រួល សុទ្ធតែមានចំណែកដោយខ្លួនតាមថ្នាក់, ការអាក្រក់នៃកាយខាងក្រៅ សេចក្តីអាក្រក់ទីងសេចក្តីទុក្ខព្រួយមិនមានចំណែកតាមថ្នាក់ឡើយ ។

- អ្នកមានទ្រព្យ សប្បាយណាស់ មើលទៅ! ព្រោះគ្មានអ្វីជាទំនប់ដល់ចិត្តចង់ ។ ចិត្តដែលត្រូវការត្រង់ណា អាចធ្វើបានត្រង់នោះដោយរីករាយ ។

- មានសេចក្តីរីករាយខ្លះ គេបានមកមិនបាច់អស់លុយកាក់ក៏មាន ។ ឯងមិនដែលដឹងទេ ដូចជាសេចក្តីសុខស្រួលនៃការសម្រាក មកពីមានកំឡាំង, ស៊ីឆ្ងាញ់មកពីឃ្លាន, ផឹកបានមកពីស្រេក, សេចក្តីសប្បាយកើតឡើងពីចិត្តស្រឡាញ់ នឹងកើតឡើងព្រោះមានគេស្រឡាញ់ខ្លួន ករណីនេះក៏មកតែពីអត់យូរពេកនឹងស៊ូបរជីវិត ។ អ្នកមានទ្រព្យដែលប្រាសចាកសេចក្តីសុខទាំងនោះ មកពីមានការប្រយ័ត្នដល់សេចក្តីត្រូវការទៅ

អនាគត ។ សេចក្ដីអផ្សុកធុញទ្រាន់មកពីផ្អែតពេក ការផ្ទើនផ្ទៃមកពីមានធនធានច្រើនហើយអត់អ៊ីបន្ដិចមិនបាន រហូតដល់ការសប្បាយធំក៏គេមិនពេញចិត្តដែរ ។ ផ្កាកុលាបមួយពាន់ក្រអូបស្រស់បានតែមួយខណៈ ចំណែកបន្លាកុលាបវិញតែមួយ បើមុតឈឺចាប់ណាស់ ។ សេចក្ដីទុក្ខតែមួយកើតមានឡើងនៅកណ្ដាលនៃសេចក្ដីសប្បាយរីករាយ នៃពួកអ្នកមានទ្រព្យ ដូចជាបន្លាមួយនៅកណ្ដាលនៃផ្កាកុលាបទាំងឡាយ ។ ចំណែកអ្នកខ្សត់វិញ មិនដូច្នោះឡើយ សេចក្ដីរីករាយតែមួយកើតឡើងនៅកណ្ដាលនៃសេចក្ដីទុក្ខទាំងឡាយ ដូចជាផ្កាមួយនៅកណ្ដាលនៃបន្លាទាំងឡាយ, គេរស្វាយសេចក្ដីសប្បាយរីករាយនោះដោយចិត្តក្លាហាន ។ រឿងនេះបានជាមានលេចឡើងខ្លាំងដោយសារការជួយគ្នា ។ ធម្មតាៈលោកបានថ្លឹងហើយជាស្រេច ។ ភាពទីមួយជារបស់នៃអ្នកមានទ្រព្យ ភាពទីបន្ទាប់ជារបស់នៃអ្នកខ្សត់ ។ តែក្នុងភាពទាំងពីរនេះ មនុស្សសុទ្ធតែត្អូញត្អែរមិនឈរទប់ទល់បាន ព្រោះសេចក្ដីសុខស្រួល សំដៅយកត្រង់ការជាទុះបេក្ខានិងមានចិត្តធម៌ ។

•

— ចុះយ៉ាងដូចម្ដេចហៅ ចិត្តធម៌?

— នែកូន! អ្នកធ្វើការដើម្បីចិញ្ចឹមម្ដាយនិងញាតិ ហើយមិនត្រូវការចង់ឲ្យអ្នកណាដឹង អ្នកណាសរសើរទេ ។ ចិត្តធម៌គឺជាកម្លាំងមួយកើតឡើងដោយញាណសម្បយុត្តអសំខារិក ដើម្បីបំពេញកិច្ចជាកុសលដល់អ្នកដទៃ ប្រាថ្នាចង់ឲ្យត្រូវនឹងព្រះជាម្ចាស់តែម្យ៉ាង ។ (មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

លោក ជាប-ពិន ថ្លែងតាមវិទ្យុ ប្រទេសកម្ពុជា

ពីថ្ងៃទី ២៨ - ២ - ៥៣ ព.ស. ២៤៩៥

## ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

អស់លោកទាំងឡាយ !

ឱកាសនេះ ខ្ញុំបាទតាងនាមពុទ្ធសាសនបណ្ឌិត្យ បានកិត្តិយសមកបរិយាយអំពីបុណ្យមាឃបូជា តាមអត្ថបទដែលព្រះតេជព្រះគុណព្រះញាណកោសលញាណ ឈឹម ក្រុមជំនុំព្រះត្រៃបិដក រៀបរៀងជូនជាប្រដាប់សតិបញ្ញាការបេះដូងរបស់ពុទ្ធបរិស័ទតទៅ :—

- អស់លោកទាំងឡាយបានជ្រាបហើយថា ថ្ងៃ ១៥ កើត ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំដែលជាបវេណីមួយរបស់ព្រះពុទ្ធសាសនា សម្រាប់ពុទ្ធបរិស័ទធ្វើពុទ្ធបូជា ហើយជាថ្ងៃបុណ្យ ដែលកម្ពុជរដ្ឋបានត្រាទុកជាបវេណីរបស់ប្រទេស សម្រាប់ប្រជាជនខេមរជាតិធ្វើសក្ការបូជា តាំងពីបុរាណកាល, - ព្រះរាជរដ្ឋាភិបាលយើង តាំងពីរជ្ជកាលព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ - មុនីវង្ស មក ក៏បានសង្គ្រោះចូលជាថ្ងៃបុណ្យតាមផ្លូវការដូចបុណ្យទាំងពួង ។

ដោយថ្ងៃពេញបូណ៌ ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំឧត្តមមួយសម្រាប់កម្ពុជរដ្ឋដូចរៀបរាប់មកហើយ បានជាតែដល់ថ្ងៃនេះកាលណាតែងឃើញ

បណ្ដាពុទ្ធបរិស័ទជាតិខ្មែរយើងទាំងគ្រហស្ថទាំងបព្វជិត បញ្ជប់ការបលិពោធនាំគ្នាធ្វើពុទ្ធបូជាតែរៀងខ្លួន ៗ ឧបាសក ឧបាសិកា គ្រប់ភូមិស្រុកសឹងស្ទើរតែពាក់ស្អាតបាត នាំគ្នាកាន់គ្រឿងសក្ការៈដើរជាពួកជាគងចូលទៅកាន់វត្តអារាមធ្វើពុទ្ធបូជា ជាឧឡារិក ដោយសេចក្ដីជ្រះថ្លាយ៉ាងអស្ចារ្យគ្រប់គ្នា ព្រោះក្នុង ១ ឆ្នាំមានធ្វើបុណ្យមាឃបូជាតែម្ដង ។

បុណ្យមាឃបូជា យើងជាពុទ្ធបរិស័ទគួរជ្រាបដូចរៀបរាប់តទៅនេះ :–.

បុណ្យមាឃបូជា ប្រែថា "បុណ្យថ្វាយគ្រឿងសក្ការៈចំពោះព្រះរតនត្រ័យ ត្រង់ថ្ងៃពេញបូណ៌ ខែមាឃ" ដោយមានគោលសំខាន់ ២ ប្រការ គឺ

<u>គោលសំខាន់ទី ១</u>: បុណ្យមាឃបូជា គឺជាបុណ្យរំលឹកដល់ថ្ងៃពេញ-បូណ៌ ខែមាឃ នៃឆ្នាំរកាសប្ដស័ក មុនពុទ្ធសករាជ ៤៤ ឆ្នាំ ជាថ្ងៃនក្ខត្ត-ឫក្សធំ ១ របស់ព្រះសក្យមុនីបរមគ្រូរបស់យើង ដែលមានតែម្ដងក្នុងរវាងពុទ្ធកាលរបស់ព្រះអង្គមាន ៤៥ ព្រះវស្សា ។

ដ្បិតមានដំណាលថា: ក្នុងបឋមពោធិកាល គឺឆ្នាំដែលព្រះសម្មា-សម្ពុទ្ធបរមគ្រូរបស់យើងទើបនឹងត្រាស់ដឹងថ្មីៗ ក្រោយពេលដែលព្រះសារីបុត្រ និងព្រះមោគ្គល្លានបានសម្រេចសាវកបារមីញាណរួចហើយ ព្រះពុទ្ធអង្គទ្រង់ស្ដេចចុះតាកក្កុដិជ្ឈកូដ មកកាន់វត្តវេឡុវ័នជិតក្រុងរាជគ្រឹះ

ទ្រង់ប្រថាប់កណ្ដាលទីប្រជុំព្រះវិសុទ្ធិសង្ឃ អង្គព្រះអរហន្តចំនួន ១.២៥០ អង្គជាទីប្រជុំប្រកបដោយអង្គ ៤ ហៅថា "ចាតុរង្គសន្និបាត" ព្រះអង្គទ្រង់តាំងព្រះសារីបុត្រជាអគ្គសាវ័កស្ដាំ ព្រះមោគ្គល្លានជាអគ្គសាវ័កឆ្វេង ហើយ ទ្រង់សំដែងនូវឱវាទបាតិមោក្ខកណ្ដាលទីប្រជុំនោះ ។

ចាតុរង្គសន្និបាត ជាបវេណីរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ តាំងអំពីបុរាណរៀងមក ប៉ុន្តែព្រះអង្គខ្លះមានតិចដង ព្រះអង្គខ្លះមានច្រើនដង ហើយនឹងព្រះសង្ឃសាវ័កដែលមកប្រជុំនោះ អង្គខ្លះមានចំនួនតិច អង្គខ្លះច្រើនជាងគ្នាប៉ុណ្ណោះ ។ ឯព្រះសម្មាសម្ពុទ្ធបរមគ្រូយើងមានតែម្ដង ហើយចំនួនព្រះអរហន្តសាវ័កមានត្រឹមតែ ១.២៥០ អង្គ ។

ការជួបជុំសាវ័កគ្រានោះ បានជាហៅថា "ចាតុរង្គសន្និបាត" ព្រោះជាការជួបជុំប្រកបដោយអង្គ ៤ គឺ

ក) ថ្ងៃពេញបូណ៌មី ខែមាឃ ជាថ្ងៃឧបោសថ;

ខ) ព្រះអរហន្តទាំង ១.២៥០ អង្គបានមកជួបជុំឯងៗ មិនបាច់នរណានិមន្ត;

គ) ព្រះអរហន្តទាំងនោះ សុទ្ធតែជាព្រះខីណាស្រពសម្រេចអភិញ្ញាទាំង ៦ គ្រប់ព្រះអង្គ;

ឃ) ព្រះអរហន្តទាំងនោះ សុទ្ធតែជាឯហិភិក្ខុបួសផ្ទាល់ព្រះពុទ្ធអង្គ ដោយមានសក់ពុកមាត់ពុកចង្កាកោរស្រាប់ៗ មានបាត្រនិងត្រៃចីវរសម្រេចដោយបុញ្ញឫទ្ធិស្រាប់ៗគ្រប់ព្រះអង្គ ។

<u>គោលសំខាន់ទី ២</u> ៖ បុណ្យមាឃបូជា គឺ ជាបុណ្យរំលឹកដល់ថ្ងៃពេញបូណ៌មី ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំមួយទៀត មុនពុទ្ធសករាជចំនួន ៣ ខែ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ប្រជុំសាវ័កដាក់ព្រះជន្មាយុសង្ខារ របស់ព្រះអង្គ ។

សឹងមានដំណាលថា៖ គ្រាបច្ឆិមពោធិកាលដែលព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងបច្ឆិមវ័យ មុនថ្ងៃបរិនិព្វាន ៣ ខែ ព្រះអង្គទ្រង់ប្រថាប់នៅនាចាបាលចេតិយ ។

វេលានោះ ក្រុងមារចិត្តបាបមកនិមន្តឲ្យព្រះអង្គឲ្យបរិនិព្វាន, ព្រះអង្គទ្រង់មានព្រះបន្ទូលនឹងមារថា

“នែមារ! អ្នកកុំបាច់ខ្វល់ខ្វាយ, មិនយូរប៉ុន្មាននៅតែ ៣ ខែទៀតទេ តថាគតនឹងបរិនិព្វានហើយ” ។

កាលទ្រង់កំណត់ព្រះជន្មរបស់ ហៅថា “ដាក់ព្រះជន្មាយុសង្ខារ” ព្រះពុទ្ធដីកានេះ ត្រង់លើថ្ងៃពេញបូណ៌មីខែមាឃដូចថ្ងៃចាតុរង្គសន្និបាតដែរ ប៉ុន្តែថ្ងៃពេញបូណ៌មីខែមាឃ កាលចាតុរង្គសន្និបាត នៅក្នុងបឋមពោធិកាល គឺវេលាព្រះអង្គទើបនឹងបានត្រាស់ នាព្រះជន្ម ៣៥ ឆ្នាំ; ថ្ងៃពេញបូណ៌មីខែមាឃ កាលទ្រង់ដាក់ព្រះជន្មាយុសង្ខារ នៅក្នុងបច្ឆិមពោធិកាល គឺវេលាព្រះអង្គជិតបរិនិព្វាន នាព្រះជន្មគម្រប់ ៨០ ឆ្នាំ ព្រះវស្សាគម្រប់ ៤៥ ប៉ុណ្ណោះ ។

វេលាទ្រង់ដាក់ព្រះជន្មាយុសង្ខារនោះ មានការកក្រើកអំពើកញ្ញាប់ញ័រផែនដីយ៉ាងធំ គួរក្តុកក្តួលព្រឺពោមព្រឺស្បែក ទាំងមហាមេឃក៏ខ្ទរទឹមមានផ្គរលាន់ឮសឹងកង់រំពង ជាមហាអស្ចារ្យ ។

អាស្រ័យដោយថ្ងៃពេញបូណ៌មី វិសាខ ជាថ្ងៃមានគោលសំខាន់ ២ យ៉ាងដូចបរិយាយមកនេះហើយ បានជាពុទ្ធបរិស័ទគ្រប់ប្រទេសដែលកាន់ព្រះពុទ្ធសាសនា ទុកថ្ងៃនេះជាទិវាកិលក្ខិតធំមួយសម្រាប់ពុទ្ធបរិស័ទរៀបគ្រឿងសក្ការបូជាថ្វាយព្រះរតនត្រ័យ ជាបវេណី ពល់ប្រទេស, ទាំងប្រទេសកម្ពុជាយើងក៏បានទុកថ្ងៃនេះ ជាបវេណីរបស់ប្រទេសដូចគ្នា ។

ប្រសិនបើមានបញ្ហាកើតឡើងថា ការធ្វើមាឃបូជាមានប្រយោជន៍យ៉ាងណាខ្លះ?

សូមឆ្លើយឲ្យហើយថា មានប្រយោជន៍យ៉ាងនេះ គឺ

១ – ប្រយោជន៍ជាករណីយកិច្ចដ៏ប្រពៃមួយយ៉ាង របស់ពួកពុទ្ធបរិស័ទដែលត្រូវតែរំលឹក ដល់ថ្ងៃនក្ខត្តឫក្ស ជាគោលសំខាន់នៃពុទ្ធសាសនា ហើយនឹងបានថ្វាយសក្ការបូជា ចំពោះព្រះរតនត្រ័យនាថ្ងៃនក្ខត្តឫក្សនោះ តាមគាប់អធ្យាស្រ័យ ដើម្បីជាកស្តុតាងបង្ហាញពិភពលោកឲ្យឃើញជាក់ថា ប្រទេសកម្ពុជា ជាប្រទេសប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងជាក់ស្តែង ។

២ – ប្រយោជន៍ឲ្យពួកពុទ្ធបរិស័ទ ដែលបានមកធ្វើសក្ការបូជានោះកើតមានសេចក្តីសាមគ្គីស្មោះស្ម័គ្រគ្នា ដើម្បីលះបង់នូវបដិឃៈកំហឹងសន្តាន

ដែលធ្លាប់មានមករវាងពុទ្ធបរិស័ទផងគ្នា ដោយសារពេលដែលជួបជុំនោះ នាំគ្នានឹកពរគុណពុទ្ធគុណជាអារម្មណ៍តែមួយយ៉ាង;

៣- ប្រយោជន៍បានគន្លងបវេណីធម៌ដ៏ថ្លៃថ្លា នៃព្រះពុទ្ធសាសនា ដើម្បីញុំាងពពួកយុវជនពុទ្ធបរិស័ទ កូនអនាគតឲ្យចេះតែជឿជាក់ថា ថ្ងៃពេញបូណ៌មីខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំ សម្រាប់ពុទ្ធបរិស័ទប្រជុំធ្វើពុទ្ធបូជា ជាទំនៀមក្នុងព្រះពុទ្ធសាសនាតទៅ មិនដាច់ខ្សែ;

៤- ប្រយោជន៍បានដាស់តឿននូវស្មារតី នៃពុទ្ធបរិស័ទក្នុងបច្ចុប្បន្ន ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹតតែជ្រះថ្លាចំពោះធម៌វិន័យពុទ្ធសាសនា តឹងរ៉ឹងឡើង តាមកម្លាំងសទ្ធារៀងខ្លួន ឲ្យមានដំហានឈានទៅខាងមុខ ជាដរាបតតថយក្រោយ ដោយនឹកឃើញដល់ដំណើររ័យនៃការប្រតិបត្តិរបស់ខ្លួនៗ;

៥- ប្រយោជន៍ជាប្រទីបត្រោលបំភ្លឺដល់ពុទ្ធបរិស័ទ ដែលពុំទាន់យល់ឲ្យបានយល់ច្បាស់ ដោយបានមកធ្វើសក្ការបូជាហើយ បានស្តាប់នូវប្រវត្តិនៃសក្ការបូជានោះថា ការធ្វើបុណ្យមាឃបូជានេះ គឺជាបុណ្យរំលឹកគុណព្រះរតនត្រ័យ ចំពោះថ្ងៃនក្ខត្តឫក្សធំៗ ទាំងពីរគ្រា គឺថ្ងៃចាតុរង្គិកសន្និបាតតាំងអគ្គសាវក និងថ្ងៃដាក់ព្រះជន្មាយុសង្ខារនៃព្រះគោតមបរមគ្រូរបស់យើងទាំងឡាយ ជាថ្ងៃដែលកន្លងថយក្រោយពីថ្ងៃនេះទៅវិញជាង ២.៤៩៥ ឆ្នាំមកហើយ ។

បរិយាយមកក្នុងអត្ថបទស្ដីពីបុណ្យមាឃបូជា ដែលបានចាត់ជាទំនៀមទម្លាប់ខ្មែរមួយយ៉ាង ខាងផ្នែកទំនៀមបុណ្យព្រះពុទ្ធសាសនា ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

ថ្ងៃមុខ ខ្ញុំបាទនឹងបរិយាយពីរឿងទំនៀមទម្លាប់ខ្មែរ មានប្រការផ្សេងៗទៀត សូមអស់លោកប្រុងចាំអានចាំស្ដាប់ ជាប្រដាប់សតិបញ្ញាការចេះដឹងតទៅ ។

## សេចក្ដីរួបរួម

ពេញបូណ៌មីខែមាឃរៀងរាល់ឆ្នាំ ជាថ្ងៃប្រចាំនក្ខត្តឫក្ស
ដែលយើងជាពុទ្ធសាសនិក គប្បីរលឹកចាំជាក់លាក់ :
មួយ — ថ្ងៃចតុរង្គសន្និបាត ដែលព្រះលោកនាថផ្ដុំសាវ័ក
ពីរ — ថ្ងៃព្រះអង្គទ្រង់បានដាក់ ព្រះជន្មចៀងជាក់នឹងនិព្វាន !

ចាប–ពិន

# សុន្ទរកថា

## លោកដុកទ័រគុណបលៈបិយៈសេនុៈម៉ាឡាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

## ពុទ្ធសាសនបណ្ឌិត្យ

(តមក)

---

## អក្សរសាស្ត្រ

អក្សរសាស្ត្រ គឺសភាពដ៏ល្អមួយយ៉ាងក្នុងកិច្ចគ្រាផ្ទុកនូវសម្ពន្ធកិច្ច ទៅវិញទៅមក ព្រមទាំងប្រយោជន៍ជាសាធារណៈ ៗ

សេចក្ដីសោមនស្សរបស់ខ្ញុំ ដ៏ពន្លឹកៈ នោះគឺខ្ញុំពិនិត្យទៅឃើញនូវសេចក្ដីចម្រើនខាងអក្សរសាស្ត្រសម្បើមអស្ចារ្យតាំងពីប៉ុន្មានឆ្នាំមុននេះ ៗ សៀវភៅដែលបានបោះពុម្ពលក់មានចំនួនជាច្រើនម៉ឺនក្បាល, បញ្ជាក់ឲ្យឃើញនូវផលប្រយោជន៍ដ៏ពន្លឹក នៃព្រះពុទ្ធសាសនាក្នុងពិភពលោក អត្ថបទដែលបោះពុម្ពផ្សាយមានជាច្រើនបែប ៗ បចម, មានកាលិកប័ត្រជាច្រើន ខ្លះចេញក្នុងសប្ដាហៈម្ដង, ខ្លះ ១៥ ថ្ងៃម្ដង, ខ្លះមួយខែម្ដង, មានសៀវភៅខ្លះទៀតត្រីមាស, ពីរទៀតអនុសំវច្ឆរៈ សៀវភៅទាំងនោះបានបោះពុម្ពផ្សាយជាភាសាច្រើន, ភាសាខាងបូព៌ាប្រទេសទិសបស្ចិម

ប្រទេស ហើយមានចុះរឿងរ៉ាវសំខាន់ៗ ខាងព្រះពុទ្ធសាសនានឹងបញ្ហាព្រះពុទ្ធសាសនា ។

សៀវភៅនោះគេបានស្គាល់គ្រប់ៗគ្នាហើយ មានផ្សាយពាសពេញពិភពលោក ។ ខ្ញុំមិនបានពយនាមកាលិកប័ត្រនោះទេ ដោយខ្លាចក្រែងពយនាមមិនសព្វគ្រប់ក្រែបខ្វះ ។ កាលិកប័ត្រទាំងអស់ត្រូវតែយើងជួយឧបត្ថម្ភពេញលក្ខណៈ ហើយត្រូវតែយើងលើកទឹកចិត្តអ្នកដែលធ្វើ ព្រោះអ្នកទាំងនេះបានបំពេញនូវវត្ថុបំណងដ៏ប្រសើរ គួរឲ្យស្តាយពន់ពេក មានអ្នកខ្វះត្រូវស្រែកអំពាវនាវឲ្យយើងជួយមូលនិធិ ។ រឿងនេះលំបាកពន់ពេក ហើយយើងបានដឹងថា កាលិកប័ត្រដែលបោះពុម្ពផ្សាយចេញមិនបានតាមបំណង គឺជាកាលិកប័ត្រមានសភាពវិសេសជាងគេ ។ គួរឲ្យអាណិតអាសូរដល់អ្នកទាំងនេះ ដែលពឹងផ្អែកទៅលើបុគ្គលដែលមានសទ្ធាតិចតួចស្តួចស្តើងយ៉ាងដូចនេះ ។

ខុសថមួយ សម្រាប់ការពារនូវការៈបែបនេះ គឺស្ថិតនៅក្នុងការបន្ថែមចំនួនសៀវភៅ ដែលត្រូវបោះពុម្ពផ្សាយ. តែដូចជាកាលមានមកពីមុនជាញឹកញយ តម្លៃបូកផ្ទាន់សៀវភៅនីមួយៗ ច្រើនជាងតម្លៃដែលលក់ ។ លទ្ធផលនៃការបោះពុម្ពផ្សាយសៀវភៅទាំងនោះ នាំទៅកាន់សេចក្តីខាតជាបរិយោសាន ។ មធ្យោបាយគឺត្រូវស្ថាបនានូវមូលនិធិកណ្តាលសម្រាប់បោះពុម្ពផ្សាយ ព្រោះហេតុដូចនេះបានជាត្រូវមាន

ប្រាក់ជំនួយដែលត្រូវផ្តកយកសម្រាប់ផ្ញើរទៅឲ្យ កាលិកប័ត្រណាដែលត្រូវការជាដេ ។ ពិតមែនតែមានសេចក្តីលំបាកជាច្រើនប្រការ ខាងការអភិបាលនិងការផ្សេងៗ ហើយបញ្ហានេះត្រូវជ្រើសរើសដោយសេចក្តីអនុគ្រោះ ដល់កាលិកប័ត្រណាមួយ, តែមិនមែនឧបសគ្គធំណាស់ណាទេ ។ ក្រៅពីសៀវភៅបោះពុម្ពផ្សាយរឿងព្រះពុទ្ធសាសនាជាពិសេសនេះ មានសៀវភៅឯទៀតដែលបោះពុម្ពទៅតាម ទេសៈកាលៈនូវរឿងរ៉ាវដែលមានតម្លៃបំផុតខាងព្រះពុទ្ធសាសនា, ហើយនឹងពួកពុទ្ធ-សាសនិកជន, ជាហេតុឲ្យមានបញ្ហាខាងបណ្ណាល័យ ព្រមទាំងយោបល់បន្ថែមចំពោះការស្ថាបនានូវលេខាធិការដ្ឋានអចិន្ត្រៃនៃពុទ្ធិកសមាគមពិ-ភពលោក ។ ជាកិច្ចដ៏សំខាន់ ដែលឲ្យមានបណ្ណាល័យប្រកបដោយសន្ទស្សន៍ចំពោះតម្លៃនៃអត្ថបទ ដែលជ្រើសយកតែសារៈប្រយោជន៍ព្រោះមានអ្នកនិពន្ធសៀវភៅ ឬសេចក្តីពិនិត្យ អំពីព្រះពុទ្ធសាសនាច្រើនប្រព្រឹត្តខុស, ឬភាន់ច្រឡំ, ជួនកាលដោយឆន្ទៈផងក្នុងកិច្ចអ្នកនិពន្ធ ដែលមានបំណងចង់បញ្ជាក់ថា សាសនារបស់ខ្លួន មានសហភាពឧត្តុង្គឧត្តមជាងពុទ្ធោវាទ ដោយគ្មានអ្វីជាគោលសម្រាប់ដឹកនាំ មានបុគ្គលជាច្រើន ដែលពេញចិត្តខាងព្រះពុទ្ធសាសនាតែច្រើនភាន់ច្រឡំនាំឲ្យខូចប្រយោជន៍ខ្លួនព្រមទាំងខូចតម្លៃធម៌ ។

សៀវភៅនិងដែក ឬស្ពានបន្ទាស់ សម្រាប់ចារិកព្រះពុទ្ធសាសនា, មានធ្វើជាច្រើន, តែមានប្រភេទខ្លះដូចជាប្រភេទអេស្ប៉ាញ និង

ប្រទេសទាំងឡាយខាងទ្វីបអឺរុបឯកើតដែលរកសៀវភៅ ឬបន្ទាស់ស្ពាន់ចារិកព្រះពុទ្ធសាសនាមិនបាន ។ ចំពោះប្រទេសជាច្រើនខាងទ្វីបអឺរុបខាងកើត មានការគមនាគមន៍ខាងផ្លូវព្រះពុទ្ធសាសនាដោយលំបាក, តែការលំបាកនេះមិនមាននៅប្រទេសអេស្ប៉ាញសោះឡើយ ។ ប្រទេសខាងទ្វីបខាងកើតមិនបាននិយមកាប់អានព្រះពុទ្ធសាសនាច្រើន ប្រើសិទ្ធិហាមមិនឲ្យប្រជាស្ត្រ អានអក្សរសាស្ត្រពុទ្ធសាសនា ។ នេះគឺជាសភាពផ្ទុយនឹងប្រាជ្ញាដ៏ធំទូលំទូលាយនៃសតវត្សទីម្ភៃ ដែលយកពន្ធដារចំពោះវិទ្យាទាំងនេះ គឺវិទ្យាដែលមានហេតុទាក់ទងខាងផ្លូវប្រាជ្ញា ។ តែរឿងនេះមានសភាពខាងក្រៅបញ្ហាខាងលើ ហើយត្រឡប់ទៅជាចូលក្នុងអង្គការសហប្រជាជាតិសម្រាប់អប់រំការសិក្សា, វិទ្យាសាស្ត្រនិងវប្បធម៌ដែលខ្ញុំសង្ឃឹមថា អង្គការនេះនឹងយកបញ្ហាទៅដោះស្រាយតាមគួរការ ។

## អត្ថបទនិងសេចក្ដីប្រែ

ក្រៅពីគម្ពីរដើម មានអត្ថបទនឹងសេចក្ដីប្រែ ដែលបានបោះពុម្ពផ្សាយនូវព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ ។ មានគម្ពីរដែលកែប្រែទៅតាមអក្សររ៉ូម៉ាំង ឬឡាតាំងនៃព្រះត្រៃបិដក មានជាច្រើននាំមកហើយ តែសៀវភៅទាំងនោះ មានផ្នែកជាច្រើនឥឡូវចំណាយអស់ហើយត្រូវតែបោះពុម្ពសាជាថ្មី ។ ឯព្រះត្រៃបិដកភាសាបាលីមានផ្នែកច្រើន បានប្រែជាភាសាអង់គ្លេសព្រមទាំងភាសាបារាំងនិងអាល្លឺម៉ង់ ហើយមាន

ផ្នែកខ្លះទៀត ប្រែជាភាសាអីតាលី ។ សៀវភៅព្រះត្រៃបិដកទាំងនេះ ត្រូវតែបោះពុម្ពឡើងជាថ្មី ។ ខ្ញុំមានចិត្តសោមនស្សពន់ពេកដោយបាន ឃើញថាព្រះត្រៃបិដកបាលីមានអត្ថបទខាងព្រះធម៌ ចំពោះគណៈពុទ្ធ-សាសនាថេរវាទ បានប្រែជាភាសាជប៉ុននឹងភាសាចិន ។ សេចក្ដី ប្រែជាភាសាជប៉ុនបានសរសេរទាំងអស់ តែក្នុងសម័យបច្ចុប្បន្ន គេ ឃើញមានតែសៀវភៅពីរដែលមានសេចក្ដីប្រែជាភាសាចិន ។ សៀវ-ភៅពីរនេះមានប្រែជាភាសាចិនចប់ក្នុងពេលមហាសង្គ្រាមលើកមុន នេះ ត្រូវតែពិនិត្យផ្ទៀងផ្ទាត់ជាថ្មីមុននឹងយកទៅបោះពុម្ពផ្សាយ ។ ត្រង់នេះ ត្រូវគិតពីមូលនិធិជាបញ្ហាសំខាន់ ហើយដែលខ្ញុំពណ៌នានៅទីនេះព្រោះ មានចិត្តសង្ឃឹមថា គង់មានអ្នកសប្បុរសជាតិចិនខ្លះដែលមានសទ្ធាជ្រះថ្លា, អាចស្វែងរកប្រាក់ក្នុងការបោះពុម្ពសៀវភៅនេះបាន ។ ចំណែកខាង វិញជនដែលគេត្រូវការនេះ លោកប្រុងប្រៀបនឹងជួយពិនិត្យផ្ទៀងផ្ទាត់ នូវសៀវភៅនេះ ព្រោះពីរនេះមានអត្ថបទសំខាន់ៗជាច្រើន ខាងលទ្ធិមហា យាន រង់ចាំសេចក្ដីប្រែចំពោះភាសាដទៃទៀត ដូចជាភាសាអង់គ្លេស ឬភាសាបារាំង ។ ពិតមែនតែការប្រែនេះ ត្រូវផ្ដើមតាំងពីជាងមួយ សតវត្ស ក៏កិច្ចទាំងនេះនៅច្រើនណាស់ ហើយការបោះពុម្ពក៏ត្រូវបំពេញ ដោយឆាប់ហើយ ។

(មានត)

# ពិធីបុណ្យ

## ឆ្លងព្រះវិហារវត្តពោធិវាល ខេត្តបាត់ដំបង

និង

## បុណ្យចំរើនព្រះជន្មព្រះតេជព្រះគុណព្រះមុនីកោសល
## អ៊ុំ-ទូត មេគណ ខេត្តបាត់ដំបង

ព្រះមហាឧត្តមវិជ្ជា កែ-អឿន ស្តីអនុគណ

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

---

កាលនៅថ្ងៃព្រហស្បតិ៍, សុក្រ, សៅរ៍, ១១, ១២, ១៣ កើតខែពិសាខ ឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៩៦ គឺថ្ងៃទី ២៣, ២៤, ២៥ ខែមេសា គ. ស. ១៩៥៣, នៅវត្តពោធិវាលមានធ្វើពិធីបុណ្យដ៏ឧឡារិក គឺបុណ្យឆ្លងព្រះវិហារថ្មីជាន់ក្រោយ និងបុណ្យចំរើនព្រះជន្មាយុព្រះតេជព្រះគុណព្រះមុនីកោសល អ៊ុំ ទូត មេគណ គំរប់ ៦១ ឆ្នាំ ។ ការឆ្លងព្រះវិហារដែលមិនទាន់បានសម្រេចនេះ ដោយពុទ្ធបរិស័ទដែលមានវ័យចាស់ៗ តែងនឹករំពឹងដល់សង្ខារធម៌ដែលមិនទៀងទាត់ ក្រែងការកសាងវិហារនេះមិនទាន់បានសម្រេច ខ្លួនលះបង់បញ្ចក្ខន្ធទៅកាន់បរលោកនាយ ទៅមិនទាន់បានឆ្លងកុសលនេះ ទើបធ្វើបុណ្យឆ្លងបង្ការទុកទាន់ខ្លួនមាន

ជីវិតរស់នៅឡើយហើយ ។ កាលវត្តបំណាងនេះកើតមានហើយក៏ចាត់ចែងវិធានការតាំងគ្រឿងសក្ការបូជាដល់ព្រះរតនត្រ័យ ក្នុងផ្ទៃវត្តពោធិវាលទាំងមូល វិចិត្ររចនាប្លែកៗ គឺ: នៅមាត់ផ្លូវដែលចូលទៅកាន់វត្ត មានផ្ទើក្លោងទ្វារមួយវិចិត្ររចនាដោយគ្រឿងលំអផ្សេងៗ នឹងភ្លើងអគ្គិសនីបំពេញស្រស់ចិញ្ចែងចិញ្ចាចនឹងប្រដាប់ដោយទង់ជាតិទង់សាសនា, នៅក្លោងទ្វារនោះមានចារឹកអក្សរថា "សូមគោរព សម្តេចព្រះមហា-សុមេធាធិបតី" ។ នៅត្រង់កំពែងវត្តមានផ្ទើក្លោងទ្វារមួយទៀត តាក់តែងគ្រឿងលំអនឹងអំពូលភ្លើងអគ្គិសនីបំពេញពន្លឺខៀវ - ស - ក្រហម - លឿងជាច្រើន, ក្នុងទីវត្តទាំងមូលសុទ្ធតែសំអាតគ្រប់កន្លែង គឺនៅទីព្រះវិហារថ្មី មានផ្ទើកជីវិតព័ទ្ធជុំវិញខ្ទាត់ខ្ទែងតែងដោយស្លឹកឈើស្រស់ មានទង់ជាតិ ទង់សាសនាធំៗ ចងជុំវិញ ព្រះវិហារ; នៅជ្រុងព្រះវិហារខាងក្រៅទាំង ៤ ទិស មានរោងរៀបតាំងតុសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យ រោងទាំងនោះសុទ្ធតែតាក់តែងប្លែកៗពីគ្នា ។ ខាងក្នុងព្រះវិហារនៅល្វែងកណ្តាល មានរៀបចំគ្រឿងសក្ការបូជា, នៅល្វែងខាងត្បូងរៀបអាសនៈ សម្រាប់ព្រះសង្ឃ, ល្វែងខាងជើងនឹងកណ្តាល សម្រាប់ពុទ្ធបរិស័ទ ។

នៅជ្រុងព្រះវិហារចាស់ខាងក្រៅទាំង ៤ ទិស ក៏មានរោងតាំងតុរៀបគ្រឿងសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យដែរ ដោយមានវត្តទាំង ៤ គឺ:

វត្តកែវ ១ វត្តពោធិកន្ទី ១ វត្តទំរីស ១ វត្តសង្កែ ១ មកជួយរៀបចំវិចិត្ររចនាសុទ្ធតែប្លែកៗគ្នា គឺ:

• នៅខាងត្បូងព្រះវិហារបាន មានធ្វើបុស្បុក ១ កំពស់ប្រហែល ៥ម៉ែត្រ មានជណ្តើរសម្រាប់ឡើងទៅលើទាំង ៤ ទិស, នៅជុំវិញបុស្បុកមានពិជវិតវិចិត្ររចនាដោយគ្រឿងលំអផ្សេងៗ, កំពូលបុស្បុកមាន ៥ រួត សុទ្ធតែពាសដោយសពត់ទេសឯក ប្រកបដោយក្បូរក្បាច់ក្រដាសបំរុះពណ៌គ្រប់យ៉ាង, នៅជុំវិញបុស្បុកមានពាំងទីងពេនសម្រាប់ទទួលព្រះសង្ឃមានឋានន្តរស័ក្តិ និងសប្បុរសក្នុងខែត្រ ។

ក្នុងពិធីបុណ្យទាំង ៣ ថ្ងៃនេះ មានពុទ្ធបរិស័ទនឹងប្រជាជនក្នុងខែត្រជាច្រើនណែនណាន់តាន់តាប់មករដេរដាស អញ្ជើញទៅអនុមោទនាបុណ្យនិងទៅមើលកំសាន្តក្នុងពិធីបុណ្យគ្រប់ទិវារាត្រី ។

## កម្មវិធី

## ថ្ងៃទីមួយ.— ថ្ងៃទី២៣ខែមេសា គ.ស.១៩៥៣

១.- វេលាម៉ោង ៥ រសៀល រៀបគ្រឿងសក្ការបូជាព្រះរតនត្រ័យក្នុងព្រះវិហារថ្មី និងក្នុងពេងតាំងនៅជុំវិញព្រះវិហារ ។

២.- វេលាម៉ោង ៨ យប់ អញ្ជើញពួកពុទ្ធបរិស័ទជួបជុំក្នុងទីព្រះវិហារថ្មី ដើម្បីនមស្ការព្រះរតនត្រ័យ និមន្តព្រះសង្ឃចំនួន២០អង្គចំរើន

ព្រះបរិត្តឆ្លងព្រះវិហារថ្មី ហើយនិមន្តព្រះគ្រូអនុគណ កែ អឿន ស្រុក សៀមរាប សំដែងធម៌ទេសនា តាមកាលដ៏សមគួរ រួចលេងរបាំផ្សេងៗ ។

ថ្ងៃទីពីរ— ថ្ងៃទី២៤ខែមេសា គ.ស. ១៩៥៣

១.- វេលាម៉ោង ៧ និង៣០នាទី ប្រគេនយាគូចំពោះព្រះសង្ឃ;

២.- វេលាម៉ោង ១១ វេរភត្តាហារ ប្រគេនព្រះសង្ឃ;

៣.- វេលាម៉ោង ២ រសៀល រៀបគ្រឿងសក្ការៈក្នុងសាលាធម្មសភា និងតែងតាំងតុជុំវិញព្រះវិហារថ្មី;

៤.- វេលាម៉ោង ៣ និង ៣០ នាទី អញ្ជើញពុទ្ធបរិស័ទជួបជុំក្នុងទីសាលាធម្មសភា ដើម្បីនមស្ការព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃចំនួន ៦១ រូបចំរើនព្រះបរិត្តពុទ្ធមន្ត ។

បន្ទាប់មក បណ្ឌិតមហាឡាយ - អ៊ុច ថ្លែងជីវប្រវត្តិព្រះតេជព្រះគុណព្រះមុនីកោសល ។

លុះចប់ហើយ ព្រះរាជាគណៈនិងមន្ត្រីសង្ឃគ្រប់ដំណាងសូត្រជយន្តោ ប្រគេនជ័យមង្គលចំពោះព្រះតេជព្រះគុណព្រះមុនីកោសល, រួចព្រះតេជព្រះគុណព្រះមុនីកោសល និមន្តឡើងគង់លើបុស្បក ។

ព្រះតេជព្រះគុណព្រះពោធិវង្ស, ព្រះរាជាគណៈ, ឯកឧត្តមរាជប្រតិភូ និងលោកប្រតិភូបារាំង ប្រចាំខេត្តបាត់ដំបង និមន្ត អញ្ជើញ

ឡើងលើបុស្បក ប្រោះសុគន្ធវារីលើព្រះហស្តព្រះតេជព្រះគុណ ព្រះមុនីកោសល ហើយនិមន្ត អញ្ជើញចុះទៅគង់-អង្គុយគង់ទីចុំរាំវិញ ។

ព្រះតេជព្រះគុណ ព្រះមុនីកោសល កាលបានទទួលសុគន្ធវារីរួចហើយ និមន្តចុះពីលើបុស្បកមកធ្វើកិច្ចបដិសណ្ឋារៈចំពោះឯកឧត្តមរាជ-ប្រតិភូ និងលោកប្រតិភូបារាំងប្រចាំខែត្របាត់ដំបងចំនួន ១៥ នាទី ។

បន្ទាប់មក ព្រះតេជព្រះគុណព្រះពោធិវង្ស និងលោកអ្នករាជការខ្មែរ-បារាំង និមន្ត-អញ្ជើញទស្សនាកំសាន្តពេងតាំងគុជុំវិញព្រះវិហារ ។

៥.- វេលាម៉ោង ៨ យប់ អញ្ជើញពុទ្ធបរិស័ទជួបជុំគង់ទីសាលាធម្មសភា និមន្តព្រះតេជព្រះគុណពោធិវង្សសំដែងធម៌ទេសនា ។

## ថ្ងៃទីបី.— ថ្ងៃទី ២៥ ខែមេសា គ.ស. ១៩៥៣ ·

១.– វេលាម៉ោង ៧ និង ៣០ នាទី ប្រគេនយាគូចំពោះព្រះសង្ឃ,

២.– ដល់ម៉ោង ១០ និមន្តព្រះសង្ឃចំនួន ៥០០ រូប បិណ្ឌបាត,

៣.– ដល់ម៉ោង ១១ ប្រគេនភត្តាហារចំពោះព្រះសង្ឃចំនួន ៦១ រូប;

៤ – វេលាម៉ោង ៨ យប់ និមន្តព្រះបាឡាត់ពោធិកម សំដែងធម៌ទេសនា ជាការបង្ហើយបុណ្យ ។

ព្រះតេជព្រះគុណព្រះមុនីកោសល មេគណ ខែត្របាត់ដំបង សូមឧទ្ទិសថ្វាយកុសលរាសីក្នុងពេលនេះ ចំពោះព្រះប្រិយមហាក្សត្រិយ៍

ព្រមទាំងព្រះរាជវង្សានុវង្ស សូមឲ្យទ្រង់គង់នៅក្នុងសិរីរាជសម្បត្តិខាត់កយាជាសុខសាន្ត សម្រាន្តក្នុងព្រះកាយពល ដើម្បីសម្រេចព្រះរាជកិច្ច គឺព្រះមេត្តាព្រហ្មវិហារ គ្របដណ្តប់លើប្រជាជនក្នុងកម្ពុជរដ្ឋ កុំបីមានឧបសគ្គមកពាំងព្រះរាជហឫទ័យទ្រង់បានឡើយ ។

ម្យ៉ាងទៀត ព្រះរាជបំណងឯណាដែលព្រះអង្គទ្រង់យាងទៅកាន់នានាប្រទេស ដើម្បីទាមទារតវ៉ាយកឯករាជ្យឲ្យបានបរិបូណ៌ ដល់ប្រទេសកម្ពុជា ព្រះរាជបំណងនោះ សូមឲ្យបានសម្រេចកុំបីអាក់ខានឡើយ, និងសូមឲ្យអសន្តិសុខ ដែលកើតនៅក្នុងប្រទេសស្ងប់ទៅ ដោយតេជៈនៃព្រះរតនត្រ័យនិងកុសលដ៏ប្រសើរក្នុងពេលនេះ ។